ខុមហ្វ្រែល COMFREL

ព្រឹត្តិបត្រ ខុមហ្វ្រែល

# អ្នកឃ្លាំមើល
# NEAK KLOAMMEUL

លេខ ៣៦ ឆ្នាំទី១០ ចេញថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨

## ការបោះឆ្នោតតាមលក្ខណៈប្រជាធិបតេយ្យអាស្រ័យមាន
## ការចូលរួមពីអ្នកមានសិទ្ធិបោះឆ្នោតគ្រប់ៗគ្នា

## អ្នកបោះមានការលំបាករកឈ្មោះក្នុងបញ្ជីបោះឆ្នោត

### មាតិកា

★ *ការវាយតំលៃចុងក្រោយលើដំណើរការបោះឆ្នោតឆ្នាំ២០០៨*

★

អ្នកឃ្លាំមើល : ការផ្សាយរបស់គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា

# ការវាយតំលៃចុងក្រោយ
# លើដំណើរការបោះឆ្នោតឆ្នាំ២០០៨

(របាយការណ៍នេះត្រូវបានប្រែសំរួលសង្ខេបចេញពីរបាយការណ៍វាយតំលៃចុងក្រោយលើដំណើរការបោះឆ្នោតឆ្នាំ២០០៨របស់ខុមហ្វ្រែល)

## សេចក្តីសង្ខេបនៃការរកឃើញសំខាន់ៗ

karrkeXj sxan2rbs xmERhl

ខាងក្រោមនេះជាខ្លឹមសារសង្ខេបនៃសេចក្តីសន្និដ្ឋានរបស់ខុមហ្វ្រែលទៅលើដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០០៨ ដោយបានធ្វើការអង្កេតទៅលើមណ្ឌលខេត្ត-ក្រុងសំខាន់ៗ ហើយធ្វើការប្រៀបធៀបនឹងដំណើរការបោះឆ្នោតឆ្នាំ២០០៣ លើទិដ្ឋភាពមួយចំនួន។

*បរិយាកាសសន្តិសុខ*

ចំនួនករណីនៃអំពើហិង្សា ការគំរាមកំហែង ការបំភិតបំភ័យមានការថយចុះ បើប្រៀបធៀបនឹងការបោះឆ្នោតលើកមុន ប៉ុន្តែ បរិយាកាសភ័យខ្លាចជាទូទៅនៅមានកំរិតខ្ពស់នៅឡើយ។ ខុមហ្វ្រែលបានរកឃើញករណីនៃការសម្លាប់ និងការគំរាមកំហែង ចំនួន ៥៨ករណី (ក្នុងនោះ ២៣ករណីជាការសម្លាប់មានចរិកនយោបាយ) ហើយមានករណីធ្ងន់ធ្ងរចំនួន១ ដែលជាប់ពាក់ព័ន្ធនឹងរឿងនយោបាយ គឺករណីសម្លាប់លោក **ឃឹម សំបូរ** សមាជិកអ្នកសារព័ត៌មាន គាំទ្រគណបក្សសម រង្ស៊ី និងកូនប្រុសរបស់លោកនៅក្នុងអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោត។

*អព្យាក្រឹតភាពមន្ត្រីរាជការ និងការប្រើប្រាស់ធនធានរបស់រដ្ឋ*

ដោយប្រៀបធៀបនឹងការបោះឆ្នោតឆ្នាំ២០០៣ យើងឃើញមានការកើនឡើងនូវចំនួនមន្ត្រីរាជការ នគរបាលជាតិ កងយោធពលខេមរភូមិន្ទគ្រប់លំដាប់ថ្នាក់ ដែលបានបង្ហាញកាន់តែសកម្មជាងមុន ក្នុងការចូលរួមគាំទ្រយុទ្ធនការឃោសនា ការពង្រឹងបណ្តាញគណបក្សប្រជាជនកម្ពុជា។ ចំណុចដែលគួរឱ្យចាប់អារម្មណ៍នោះគឺ អភិបាលខេត្ត-ក្រុងទាំង២៤ខេត្ត-ក្រុង ៩៨%នៃមេឃុំ ចៅសង្កាត់ និងមេភូមិចំនួន ១៣៧៥៥ សុទ្ធតែជាសមាជិកមន្ត្រីជាន់ខ្ពស់ និងជាសមាជិកសមកម្មរបស់គណបក្សប្រជាជនកម្ពុជា។

*ការចុះឈ្មោះអ្នកបោះឆ្នោត បញ្ជីបោះឆ្នោត ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត និងការចេញទំរង់១០១៨*

ចំនួនអ្នកដែលចេញទៅបោះឆ្នោតជួបឧបសគ្គផ្សេងៗ ការរារាំង និងភាពស្មុគស្មាញហួសហេតុនៃនីតិវិធីគឺមានការកើនឡើងនៅក្នុងដំណើរការចុះឈ្មោះអ្នកបោះឆ្នោត ការសំអាតបញ្ជីឈ្មោះ និងជាពិសេសនៅថ្ងៃបោះឆ្នោតតែម្តង ។ ក្នុងការបោះឆ្នោតជាតិឆ្នាំ ២០០៨នេះ យើងឃើញមានភាពមិនប្រក្រតីមួយទៀតពាក់ព័ន្ធនឹងការចេញទំរង់១០១៨។

*ការចុះបញ្ជីបេក្ខជនគណបក្សនយោបាយ*

ក្នុងដំណើរការនេះ យើងឃើញមានការបកស្រាយផ្លូវច្បាប់ខុសគ្នារវាង គ.ជ.ប និងក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងការបញ្ជាក់ពីសិទ្ធិបោះឆ្នោត និងការមានឈ្មោះក្នុងបញ្ជីបោះឆ្នោតរបស់បេក្ខជននៃគណបក្សនយោបាយ។ បេក្ខជនមួយចំនួនបាន ទទួលលិខិតបញ្ជាក់ពីមេឃុំ ចៅសង្កាត់រួចហើយ តែ បានទាមទារការបញ្ជាក់បន្ថែម និងបានធ្វើការបដិសេធបេក្ខភាព មួយចំនួនដោយផ្ទាល់ទៀតផង។ បេក្ខជនចំនួន៩៩រូប ក្នុងចំណោម២៤៧៨រូប (ឬស្មើនឹង ៤%) ត្រូវបានបដិសេធ ហើយគណបក្ស ត្រូវបាន លុបចេញពីបញ្ជីគណបក្សដែលចូលរួមក្នុងការបោះឆ្នោត។

*ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ*

ដោយប្រៀបធៀបនឹងការបោះឆ្នោតលើកមុន ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយមានការបោះជំហានទៅមុខបានបន្តិចបន្តួច។

ប៉ុន្តែនៅក្នុងដំណាក់កាលមុនបោះឆ្នោត គណបក្សប្រឆាំង និងគណបក្សមិនកាន់អំណាចផ្សេងទៀត បានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយតាមវិទ្យុបានតិចតួចតែប៉ុណ្ណោះ។ នៅក្នុងយុទ្ធនាការឃោសនា គណបក្សទាំងនេះបានត្រឹមតែប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ និងស្ថានីយ៍ឯករាជ្យខ្លះ (ដូចជាវិទ្យុសម្លេងសហរដ្ឋអាមេរិក វិទ្យុអាស៊ីសេរី វិទ្យុបារាំងអន្តរជាតិ និងវិទ្យុFM ១០២)។ ទោះជាយ៉ាងណាក៏ដោយ យ៉ាងតិចណាស់ស្ថានីយ៍វិទ្យុចំនួន៣៩ មានភាពលំអៀងខ្លាំងទៅរកគណបក្សប្រជាជនកម្ពុជាដែលកាន់អំណាច។ ស្ថានីយ៍មួយចំនួនមិនបានអនុវត្តតាមត្រឹមត្រូវតាមវិជ្ជាជីវៈ និងក្រមសីលធម៌អ្នកសារព័ត៌មាន ជាពិសេសការប្រើពាក្យពេចន៍ និងការរិះគន់ធ្ងន់ៗ ទៅលើគណបក្សប្រឆាំង/មិនកាន់អំណាច ការជជែកពិភាក្សា ពីមូលហេតុនៃការចាកចេញពីគណបក្ស និងចុះចូលគណបក្សប្រជាជនកម្ពុជាដោយមិនបើកឱកាសដល់សាមីគណបក្សដើម្បីធ្វើការបកស្រាយពន្យល់ពីស្ថានភាពជាក់ស្តែង និងការពារខ្លួន។ លោក **ដាំ សិទ្ធិ** និពន្ធនាយកសារព័ត៌មាន ត្រូវបានចាប់ខ្លួនដោយតុលាការក្រុងភ្នំពេញពីបទបរិហារកេរ្តិ៍ និងផ្សាយព័ត៌មានមិនពិតនៅ ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៨។ វិទ្យុ (FM ១០៥.២៥) ខេត្តក្រចេះត្រូវបានបិទ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៨ ដោយគ្រាន់ តែស្ថានីយ៍នេះ លក់ម៉ោងផ្សាយដល់គណបក្សនយោបាយ និងអង្គការសង្គមស៊ីវិលដោយគ្មានការអនុញ្ញាតជាមុនពីក្រសួងព័ត៌មាន។



*ការសង្កេតតាមដានព័ត៌មានតាមទូរទស្សន៍*

### *យុទ្ធនាការឃោសនាបោះឆ្នោត*

សកម្មភាពឃោសនារបស់គណបក្សនយោបាយមានភាពសកម្មជាងមុន ក្នុងនោះគណបក្សប្រជាជនកម្ពុជា ដែលមានធនធានច្រើនជាងគេ បានធ្វើសកម្មភាពឃោសនាខ្លាំងនៅទូទាំងប្រទេស ហើយក្រៅពីនេះគឺមានគណបក្ស ដែលចូលរួមប្រកួតប្រជែងចំនួន៩ផ្សេងទៀត(ឆ្នាំ២០០៣ មានតែ៣គណបក្ស)ក៏បានបើកយុទ្ធនាការឃោសនាផងដែរ។ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរដ្ឋ និងឯកជនមានភាពល្អប្រសើរជាងមុន។ ការបដិសេធពាក្យបណ្តឹង និងការទិញសន្លឹកឆ្នោតមានការថយចុះ។

ទោះជាយ៉ាងណាក៏ដោយ ជាមួយដំណាក់កាលមុនយុទ្ធនាការឃោសនាបោះឆ្នោត គណបក្សនយោបាយមិនកាន់អំណាចនៅជួបការលំបាកក្នុងការប្រើប្រាស់ទីកន្លែងសាធារណៈក្នុងសកម្មភាពឃោសនារបស់ខ្លួននៅឡើយ បរិយាកាសអសន្តិសុខ ករណីភាពមិនប្រក្រតី រួមទាំងការគំរាមកំហែង រហូតដល់ការសម្លាប់ខាង នយោបាយមានការកើនឡើង ក្នុងនោះមានករណីសម្លាប់អ្នកសារព័ត៌មានដែលគាំទ្រគណបក្សសម រង្ស៊ីជាដើម។

### *ថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត*

ចំនួននៃភាពមិនប្រក្រតីពាក់ព័ន្ធនឹងបញ្ហាបច្ចេកទេស ការរៀបចំដំណើរការបោះឆ្នោត ការដោះស្រាយពាក្យបណ្តឹងក្នុងការិយាល័យបោះឆ្នោត/រាប់សន្លឹកឆ្នោតមានការថយចុះ ដោយប្រៀបធៀបនឹងការបោះឆ្នោតឆ្នាំ២០០៣ ដែលសរុបករណីទាំងអស់មានត្រឹមតែប្រមាណ ២០០០ករណីតែប៉ុណ្ណោះ។ ការជឿនលឿនទៅមុខមួយនៃនីតិវិធីបោះឆ្នោតនោះគឺ មានការរៀបចំឧបករណ៍សម្ភារៈពិសេសសំរាប់អ្នកបោះឆ្នោតជាជនពិការភ្នែកអាចបោះឆ្នោតបានដោយខ្លួនឯងដោយវិធី ស្ទាបដោយដៃ។ ប៉ុន្តែ ភាពមិនប្រក្រតីធ្ងន់ធ្ងរមួយចំនួនដែលប៉ះពាល់ដល់សិទ្ធិបោះឆ្នោតរបស់ប្រជាពលរដ្ឋ ពិសេសការបង្កការលំបាក និងការរារាំងអ្នកបោះឆ្នោតនៅថ្ងៃបោះឆ្នោត។ ដំណើរការបូកសរុប និងផ្ទៀងផ្ទាត់លទ្ធផលរបស់គណកម្មការរៀបចំការបោះឆ្នោតថ្នាក់ឃុំ-សង្កាត់ និងថ្នាក់ខេត្ត-ក្រុង ត្រូវបានរិះគន់ថាមិនមានតម្លាភាព។

### *ការដោះស្រាយពាក្យបណ្តឹង*

ការបដិសេធពាក្យបណ្តឹងក្នុងដំណើរការបោះឆ្នោតមានការថយចុះ ពិសេសក្នុងយុទ្ធនាការឃោសនាបោះឆ្នោត។ ៤៥%នៃពាក្យបណ្តឹងសរុបចំនួនប្រមាណ២០០បណ្តឹង ត្រូវបានបដិសេធ ដែលកាលពីឆ្នាំ២០០៣ គឺការបដិសេធពាក្យបណ្តឹង មានរហូតដល់ ៨០%។ ប៉ុន្តែ នីតិវិធីនៃការទទួល និងដោះស្រាយពាក្យបណ្តឹងនៅមានបញ្ហានៅឡើយ។ និងមន្ត្រីថ្នាក់ក្រោមនៅតែសំអាងមូលហេតុដែលហៅថា " '" ដើម្បីបដិសេធពាក្យបណ្តឹង ហើយនៅតែមិនមានយន្តការស៊ើបអង្កេតបន្ថែម និងការ

ប្រមូលភស្តុតាងមុនដំណាក់កាលឈានដល់ការបើកសវនាការដោះស្រាយជាសាធារណៈ។

*ឥរិយាបថរបស់មន្ត្រីរៀបចំការបោះឆ្នោត*

ដំណើរការរៀបចំការបោះឆ្នោតជាទូទៅគឺអនុវត្តតាមប្រតិទិនបោះឆ្នោត និងតួនាទីភារកិច្ចដែលមានចែងក្នុងមាត្រា១៦នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ ទោះជាយ៉ាងនេះក្តី នៅមានកង្វះខាតតម្លាភាព និងការប្តេជ្ញា ចិត្តខាងនយោបាយក្នុងការធានាបរិយាកាសបោះឆ្នោតប្រកបដោយភាពសេរី និងយុត្តិធម៌ពាក់ព័ន្ធនឹងបញ្ហាសិទ្ធិបោះឆ្នោត ការដោះស្រាយពាក្យបណ្តឹង ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ការចេញទំរង់១០១៨ អជ្ញាធរឃុំ-សង្កាត់ និងរបាយការណ៍ស្តីពីចំណូលចំណាយរបស់គណបក្សនយោបាយ ក្នុងយុទ្ធនាការឃោសនាបោះឆ្នោត។

*ក្របខ័ណ្ឌច្បាប់បទបញ្ជា និងនីតិវិធី*

បានបើកទូលាយដល់គណបក្សនយោបាយ និងអង្គការសង្គមស៊ីវិលក្នុងការផ្តល់អនុសាសន៍ មតិយោបល់ទៅលើសេចក្តីព្រាងបទបញ្ជា និងនីតិវិធី។ ប៉ុន្តែ មិនបានធ្វើការកែលំអក្របខ័ណ្ឌច្បាប់គន្លឹះមួយចំនួនពាក់ព័ន្ធនឹង យន្តការដោះស្រាយពាក្យបណ្តឹង ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបាយការណ៍ ចំណូលចំណាយរបស់គណបក្សនយោបាយ ក្នុងយុទ្ធនាការឃោសនា បញ្ហាបញ្ជីឈ្មោះអ្នកបោះឆ្នោត ។ល។

*ការចូលរួមរបស់ប្រជាពលរដ្ឋ*

ការយល់ដឹងពីដំណើរការប្រជាធិបតេយ្យ សិទ្ធិ និងការទទួលខុសត្រូវរបស់អ្នកបោះឆ្នោតមានការកើនឡើង ទោះបីជាវាមិនអាចកាត់បន្ថយនូវការភ័យខ្លាចក្នុងចំណោមប្រជាពលរដ្ឋមួយចំនួន និងបេក្ខជនគណបក្សនយោបាយ ដែលមានសក្តានុពលក្នុងលក្ខខណ្ឌមួយចំនួនក៏ដោយ។ ចំនួនអ្នកចេញទៅបោះឆ្នោតមានចំនួនបរិមាណច្រើន ដោយសារកំណើនប្រជាជន ប៉ុន្តែបើគិតជាភាគរយនោះគឺអ្នកដែលចេញទៅបោះឆ្នោតក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៨ នេះមានចំនួនតែ៧៥%ប៉ុណ្ណោះ ដែលក្នុងការបោះឆ្នោតឆ្នាំ២០០៣មានរហូតដល់៨៣%។ ការធ្លាក់ចុះភាគរយនេះជាសញ្ញា ព្រួយបារម្ភមួយដែលគួរមានការសិក្សា ស្រាវជ្រាវដោយឡែកមួយ។ អ្នកបោះឆ្នោតដែលជួបការលំបាកឧបសគ្គផ្សេងៗការរារាំង និងនីតិវិធីស្មុគស្មាញមានការកើនឡើងក្នុងការចុះឈ្មោះអ្នកបោះឆ្នោត ការសំអាតបញ្ជី ឈ្មោះ និងនីតិវិធីថ្ងៃបោះឆ្នោត។ អ្នកបោះឆ្នោតមានការយល់ដឹងប្រសើរជាងមុនអំពីរបៀបគូសលើសន្លឹកឆ្នោតដែល ធ្វើឱ្យសន្លឹកឆ្នោតខូច និងមិនបានការ មានការថយចុះ ដែលមានចំនួនតិចជាងប្រមាណ ១,៥% តែប៉ុណ្ណោះ។

*បញ្ហាស្ត្រី*

តំណាងរាស្ត្រជាស្ត្រីដែលជាប់ឆ្នោតមានចំនួនត្រឹមតែ២០រូបប៉ុណ្ណោះ ឬស្មើនឹង១៦%នៃសមាជិករដ្ឋសភាទាំងមូល ដែលនៅឃ្លាតឆ្ងាយពីគោលការណ៍សមភាពនៅឡើយ។

*ប្រព័ន្ធបោះឆ្នោត*

ប្រព័ន្ធតំណាងសមាមាត្រ ដោយបញ្ជីគណបក្ស ដោយយកខេត្ត-ក្រុង និងរូបមន្តគណនាអាសនៈគឺមិនស្របទៅនឹងគោលការណ៍ពហុភាព និងលទ្ធិប្រជាធិបតេយ្យ។ ប្រព័ន្ធនេះ បានជួយដល់គណបក្សធំឱ្យទទួលអាសនៈច្រើនជាង សមាមាត្រនៃសន្លឹកឆ្នោតដែលទទួលបាន។ ប្រព័ន្ធនេះធ្វើឱ្យគណបក្សប្រជាជនកម្ពុជាដែលទទួលសម្លេងឆ្នោតគាំទ្រទូទាំងប្រទេសតែ ៥៨% តែបានទទួលអាសនៈរហូតដល់៧៣%នៃអាសនៈសរុបក្នុងរដ្ឋសភា (៩០/១២៣)។

## ការបោះឆ្នោត និងបរិយាកាសដែលពាក់ព័ន្ធនយោបាយ

ប្រទេសកម្ពុជានៅក្នុងឆ្នាំ ២០០៨ បានបន្តអនុវត្តបទពិសោធន៍នៃបរិយាកាសនយោបាយមួយ ដែលនាំឱ្យមានការបោះឆ្នោតមិនទាន់មានលក្ខណៈសេរី ពិតប្រាកដ និងយុត្តិធម៌ពេញលេញ។ អ្នកបោះឆ្នោត នៅតែត្រូវបានគាបសង្កត់ ដែលធ្វើឱ្យគាត់មិនអាចជ្រើសរើសគណបក្សតាមឆន្ទៈរបស់ពួកគាត់ ឬក៏ដោយសារតែមិនមានព័ត៌មានត្រឹមត្រូវគ្រប់គ្រាន់។ ប្រជាពលរដ្ឋនៅគ្រប់លំដាប់ថ្នាក់នៃសង្គម នៅតែមានភាពភ័យខ្លាចចំពោះការដាក់ទោសពីអ្នកមានអំណាច ដែលអាចប្រើអំណាចរបស់ពួកគេធ្វើឱ្យប៉ះពាល់ដល់ជីវិត

ផ្ទាល់ខ្លួន និងសង្គមគ្រួសារ ។ មានការខិតខំប្រឹងប្រែងមួយចំនួន តែនៅមិនទាន់ គ្រប់គ្រាន់នៅឡើយបានធ្វើឡើងដើម្បីបំបាត់ចោលកត្តាទាំងនេះកុំឱ្យកើតមានឡើងក្នុងការបោះឆ្នោតនៅកម្ពុជា ។

តែទោះបីជាយ៉ាងណាក៏ដោយ ខុមហ្វ្រែលបានកត់សម្គាល់ឃើញថា បរិយាកាសនៃការបោះឆ្នោតក្នុងឆ្នាំនេះ មានភាពប្រសើរ និងមានសន្តិសុខខាងនយោបាយច្រើនជាងការបោះឆ្នោតសភាជាតិកាលពីលើកមុនៗ ។

តួលេខនៃករណីឃាតកម្ម ករណីបំភិតបំភ័យ ការគំរាមកំហែង និងភាពមិនប្រក្រតីនៅក្នុងការបោះឆ្នោត មានការថយចុះជាងការបោះឆ្នោតមុនៗ ប៉ុន្តែការបោះឆ្នោតលើកនេះ នៅតែកើតមាននូវបរិយាកាសនៃការភ័យខ្លាច ។ ការស៊ើបអង្កេត និងការកាត់ទោសមិនបានធ្វើឡើងឱ្យបានឆាប់រហ័សទេ ហើយវាបែរជាពង្រឹងនូវនិទណ្ឌភាពថែមទៀត ។ ការអង្កេតបានរកឃើញថា នៅតែមានការដាក់គំនាប និងគំរាមកំហែងជាពាក្យសំដី ពិសេសពីសំណាក់គណបក្ស កំពុងកាន់អំណាច (គណបក្សប្រជាជនកម្ពុជា) ។

ចាប់ពីខែកក្កដា ឆ្នាំ២០០៧ រហូតដល់ថ្ងៃចាប់ផ្តើមបើកយុទ្ធនាការឃោសនាបោះឆ្នោត មានអំពើឃាតកម្មចំនួន ១៥ ករណីលើសមាជិក សកម្មជន និងអ្នកគាំទ្រគណបក្សនយោបាយ ។ បើប្រៀបធៀបក្នុងឆ្នាំ ២០០៧ មាន ៩ ករណី ឆ្នាំ ២០០៣ មាន ២៨ ករណី និងឆ្នាំ២០០២ មាន ១៨ ករណី ។ មានច្រើនជាង ១៨៧ ករណី នៃ ការបំភិតបំភ័យ ការសម្លុតគំរាមកំហែង ដូចជាករណីបាញ់បោះ គំរាមសម្លាប់អាយុជីវិត និងការយាយីរំខាន (ប្រៀបធៀបនឹង ឆ្នាំ ២០០៦ មាន ១២៧ ករណី ហើយឆ្នាំ ២០០៣ មាន ២៩១ ករណី និងឆ្នាំ ២០០២ មាន ១៣៨ ករណី) ។ ទោះបីជា យ៉ាងណា គេនៅមិនទាន់អាចវាស់វែងពីផលប៉ះពាល់នៃករណីទាំងឡាយនៅក្នុងឆ្នាំ ២០០៨ ទៅលើការបោះឆ្នោតនៅឡើយទេ ។

តាមរបាយការណ៍អង្កេតរបស់បណ្តាញ ខុមហ្វ្រែល បង្ហាញថា ចាប់តាំងពីការបោះឆ្នោតចាប់ផ្តើម (ដោយយោងតាមប្រតិទិនបោះឆ្នោត ដែលគិតពីការចុះឈ្មោះអ្នកបោះឆ្នោត រហូតដល់ការប្រកាសលទ្ធផលការបោះឆ្នោត) ឧប្បត្តិហេតុទាក់ទងនឹងការបោះឆ្នោត មានកើតឡើងនៅក្នុង : ករណីច្រើនបំផុតនៅក្នុងខេត្តបន្ទាយមានជ័យ ខេត្តកំពង់ចាម រាជធានី ភ្នំពេញ និងខេត្តព្រៃវែង បន្តបន្ទាប់មក(ករណីខ្លះ) មាននៅក្នុងខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តកណ្តាល ខេត្តកំពត និងខេត្តតាកែវ ។ ខេត្តកំពង់ធំ ខេត្តក្រចេះ ខេត្តសៀមរាប ខេត្តពោធិសាត់ និងខេត្តស្វាយរៀង បានសង្កេត ឃើញមានករណីមួយចំនួនដែរ ។ ករណីតិចតួចមានឃើញនៅក្នុងខេត្តកោះកុង ក្រុងព្រះសីហនុ ខេត្តព្រះវិហារ ខេត្តមណ្ឌលគីរី ខេត្តឧត្តរមានជ័យ ខេត្តរតនគីរី ក្រុងប៉ៃលិន និងខេត្តស្ទឹងត្រែង ។









សមាជិកនៃគណបក្សដែលមិនកាន់អំណាច ពិសេសគណបក្សសមរង្ស៊ី គឺជាអ្នករងគ្រោះច្រើនជាងគេពីឧប្បត្តិហេតុទាក់ទងនឹងការបោះឆ្នោត ។ គណបក្សនរោត្តមរណឫទ្ធិ ជាអ្នករងគ្រោះទីពីរច្រើនជាងគេ ។

*ករណីឃាតកម្ម*

យោងតាមការស៊ើបអង្កេតនៅក្នុងអំឡុងពេល ខែកក្កដា ២០០៧ ដល់ ខែមិថុនា ២០០៨ មានឃាតកម្ម ២៣ ករណីលើសកម្មជននយោបាយ ។ ក្នុងកំឡុងពេលចុះឈ្មោះបេក្ខជន និងគណបក្សនយោបាយ យ៉ាងហោចណាស់ ក៏មាន ឃាតកម្ម ១៥ ករណីដែលបានកើតឡើងមកលើសកម្មជនគណបក្សនយោបាយ[១] ។ករណីឃាតកម្មមួយបានកើតឡើង កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៨ លើរូបលោក **ស៊ុក រ៉ូណា** អាយុ ៤៧ ឆ្នាំ ជាសកម្មជនគណបក្សនរោត្តមរណឫទ្ធិ រស់នៅក្នុងឃុំបន្ទាយដែក ស្រុកគៀនស្វាយ ខេត្តកណ្ដាល[២] ។ បន្ថែមពីនេះទៀត គណបក្សនរោត្តមរណឫទ្ធិបានអះអាងថា កាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំ២០០៨ សកម្មជនរបស់ខ្លួន **ឈួន សោម** ដែលបានរត់ចោលគណបក្សប្រជាជនកម្ពុជា នៅ ក្នុងភូមិតាអូ ស្រុកគីរីវង្ស ខេត្តតាកែវ ក៏ត្រូវបានសម្លាប់ក្រោយពីមានជម្លោះជាមួយនឹងអតីតមន្ត្រីប៉ូលីសមួយរូបដែរ ។ចាប់ពីខែកក្កដា២០០៧រហូតដល់ថ្ងៃចាប់ផ្ដើមយុទ្ធនាការបោះឆ្នោត មានឃាតកម្មចំនួន

១ ចាប់ពីថ្ងៃ១ ខែ កក្កដា ឆ្នាំ២០០៧ ដល់២៥ ខែ មិថុនា ឆ្នាំ២០០៨(របាយការណ៍សង្កេតការណ៍របស់ ខុមហ្វ្រែល និងអាដហុក)
២ តាមសេចក្ដីរាយការណ៍របស់សមាគមការពារសិទ្ធិមនុស្សអាដហុក

១៥ ករណី លើសមាជិក សកម្ម ជន និងអ្នកគាំទ្រគណបក្សនយោបាយ ។ ៧ ករណី ជាឃាតកម្មជាប់ទាក់ទងនឹងសមាជិកគណបក្សសមរង្ស៊ី ៣ ករណី ទាក់ ទងនឹងសមាជិកគណបក្សនរោត្តមរណឫទ្ធិ ៤ ករណី ទាក់ទងនឹងសមាជិកគណបក្សប្រជាជនកម្ពុជា និង ១ ករណីចុង ក្រោយទាក់ទងនឹងសមាជិកគណបក្សសិទ្ធិមនុស្ស។

### *ការគំរាមកំហែង បំភិតបំភ័យ និងអំពើហិង្សា*

មកទល់នឹងថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៨ សកម្មជនគណបក្សនយោបាយខ្លះ ដែលភាគច្រើនមិនមែនមកពី គណបក្សកំពុងកាន់អំណាច បានទទួលរងនូវការគំរាមកំហែង : ៣២ ករណី លើគណបក្សសមរង្ស៊ី ២ ករណី លើគណបក្ស ហ៊្វុនស៊ិនប៉ិច ១២ ករណីលើគណបក្សនរោត្តមរណឫទ្ធិ ៨ ករណី លើគណបក្សសិទ្ធិមនុស្ស និង ៣ ករណី ទៀតកើតលើ គណបក្សដទៃ។ យោងតាមការអង្កេតរបស់ខុមហ្វ្រែល ករណីទាំងនោះ បានកើតឡើងភាគច្រើននៅក្នុង ខេត្តបន្ទាយ មានជ័យ ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តកំពង់ធំ និងខេត្តកណ្តាល ។ តួលេខនៃករណីទាំងនេះកើនឡើង ជាពិសេសនៅតាមតំបន់ជនបទ ។

### *ឥទ្ធិពលនយោបាយមកលើតុលាការ : ការឃាត់ឃាំង និងការបញ្ឈប់*

នៅមុនពេលយុទ្ធនាបោះឆ្នោតបានចាប់ផ្តើម មានការបារម្ភពាក់ព័ន្ធនឹងឥទ្ធិពលនយោបាយមកលើតុលាការយុត្តិធម៌ និងការអនុវត្តច្បាប់ ការប្រើប្រាស់កងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួន។ល។[៣] ជាពិសេស មានការចាប់ឃាត់ខ្លួន ការប៉ុនប៉ងចាប់ខ្លួន និងការប្រើអំពើហិង្សាមកលើសកម្មជនគណបក្សនយោបាយ។ ករណីជាច្រើនត្រូវបានរកឃើញនៅក្នុង ក្រុងភ្នំពេញ ក្រុងប៉ៃលិន ខេត្តកំពង់ធំ ខេត្តតាកែវ និងខេត្តកំពង់ឆ្នាំង ។

ការចាប់ខ្លួនសកម្មជនគណបក្សនយោបាយដោយគ្មានដីកាពីតុលាការ និងគ្មានការស៊ើបអង្កេតស៊ីជំរៅ ដែលដឹកនាំ ទៅរកបរិយាកាសនៃការភ័យខ្លាចក្នុងចំណោមសកម្មជនគណបក្សដទៃទៀតច្រើនជាងគណបក្សកំពុងកាន់អំណាច។

តួយ៉ាង ករណីមួយ នៅផ្សារទួលគ្រៀស ស្ថិតក្នុងស្រុកបារាយណ៍ ដែលលោក **ឱួត សារ៉េន** ជាប្រធានឃុំពន្ទ្រូរ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ត្រូវបានចាប់ខ្លួន ដោយមន្ត្រីប៉ូលីសក្រោមការដឹកនាំរបស់មេប៉ូលីសស្រុកដែលគ្មានដីកាពីតុលាការ[៤]។

លោក **ដាំ សិទ្ធិ** បេក្ខជនតំណាងរាស្ត្រគណបក្សសមរង្ស៊ីមណ្ឌលភ្នំពេញ និងជានិពន្ធនាយកកាសែតមនសិការខ្មែរ បានចាប់ខ្លួនកាលពីថ្ងៃអាទិត្យ ទី៨ ខែមិថុនា ឆ្នាំ២០០៨ និងឃុំខ្លួននៅគុកព្រៃសរ។ គាត់ត្រូវបានចោទប្រកាន់ពីបទ បរិហារកេរ្តិ៍ និងការផ្សព្វផ្សាយព័ត៌មានមិនពិត ក្រោយពីការដកស្រង់សម្តីរបស់តំណាងរាស្ត្រសមរង្ស៊ី អត្ថាធិប្បាយទៅលើ លោក **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ឧប្បត្តហេតុនេះបាន កើតឡើងយ៉ាងខ្លីក្រោយពេលសុន្ទរកថារបស់លោកសមរង្ស៊ីនៅមជ្ឈមណ្ឌលប្រល័យពូជសាសន៍ បឹងជើងឯក កាលពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០០៨។ អំណះអំណាងបានធ្វើទៅលើការចោទប្រកាន់ដោយគ្មានភស្តុតាងមុនៗ ដែលធ្វើឡើងដោយភាគីដទៃទៀតដើម្បីប្រឆាំងឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ថាធ្លាប់ជាប្រធានគុកបឹងត្របែក នៅក្នុងអំឡុងពេលនារបបខ្មែរក្រហម។ កាសែត មនសិការខ្មែរបានដកស្រង់ សម្តីលោក និយាយកាលពីថ្ងៃទី ១៨ ខែ មេសា ឆ្នាំ២០០៨ ។

### *ការរារាំងសកម្មភាពគណបក្សនយោបាយ និងការរំលោភលើច្បាប់បោះឆ្នោត*

ការរារាំងសកម្មភាពគណបក្សនយោបាយ បានកើតឡើងសំដៅទៅរកគណបក្សនយោបាយជាប្រាកដ ដោយរាប់បញ្ចូលគណបក្សសមរង្ស៊ី គណបក្សសិទ្ធិមនុស្ស គណបក្សនរោត្តមរណឫទ្ធិនិងគណបក្សហ៊្វុនស៊ិនប៉ិចដែលបានធ្វើឱ្យអាក់ខាន ដល់ការអនុវត្តកិច្ចប្រជុំជាច្រើនលើក។ នៅក្នុងករណីខ្លះទៀត អាជ្ញាធរមូលដ្ឋានបានបង្ក្រាបទៅលើកិច្ចប្រជុំ និងទំលាក់ស្លាកគណបក្សនយោបាយ។ មានការប្រើហិង្សាផងដែរ នៅពេលស្លាកគណបក្សសមរង្ស៊ីបានដាក់ចុះ កាលពីថ្ងៃទី២២ ខែមិនា ឆ្នាំ ២០០៨ ហើយតំណាងរាស្ត្រគណបក្សសមរង្ស៊ីមណ្ឌលភ្នំពេញ ឯកឧត្តម **ហូ វ៉ាន់** ត្រូវបានរងរបួស។ គ្រប់ករណី ទាំងអស់ដែលបានកើតឡើងទៅលើគណបក្សដែលមិនកាន់អំណាច ភាគច្រើនគណបក្សដែលទើបតែ ស្ថាបនាថ្មី គណបក្សនរោត្តមរណឫទ្ធិ និងគណបក្សសិទ្ធិមនុស្ស។ មិនមានការស៊ើបអង្កេតដែលមានប្រសិទ្ធភាព ឬដំណោះស្រាយលើករណីទាំងនេះទេ ទាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) និងអាជ្ញាធរដែនដី បានទម្លាក់ ការទទួលខុសត្រូវឱ្យគ្នាទៅ វិញទៅមកសម្រាប់ដោះស្រាយបញ្ហា។ ការទំលាក់ចេញនូវស្លាកសញ្ញាគណ

---

៣ អង្គការ ការពារសិទ្ធិមនុស្សលីកាដូ(Cambodia League for Promotion and Defanse of Human rights) និង របាយការណ៍សិទ្ធិមនុស្សប្រចាំឆ្នាំ២០០៧អាដហុក

៤ យោងតាមសេចក្តីថ្លែងការណ៍របស់គណកម្មាធិការប្រព្រឹត្តកម្ម

បក្សនយោបាយបានកើតឡើង នៅក្នុងខេត្ត ព្រៃវែង ខេត្តតាកែវ និងខេត្តពោធិសាត់ ជាឧទាហរណ៏ មានយ៉ាងហោចណាស់ ៩ ករណី បានកើតលើស្លាកសញ្ញាគណបក្ស នរោត្តមរណឬទ្ធិ ដែលត្រូវបានគេវាយកំទេចចោល និងយ៉ាងហោចណាស់ ៧ ករណី មានការវាយកំទេចស្លាកសញ្ញា គណបក្សសមរង្ស៊ី និង ៥ ស្លាករបស់គណបក្សសិទ្ធិមនុស្ស និង ២ ផ្សេងទៀតជា របស់គណបក្សដទៃទៀត ។

## បរិយាកាសយុទ្ធនាការឃោសនាបោះឆ្នោត

ខុមហ្វ្រែល បានអង្កេតឃើញថា បរិយាកាសសន្តិសុខទូទៅក្នុងអំឡុងពេលសប្តាហ៏ទីមួយនៃយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី៤ មានភាពប្រសើរ បើប្រៀបធៀបនៅក្នុងរយៈពេលដូចគ្នានៃការបោះឆ្នោត ឆ្នាំ២០០៣។ ទោះជាយ៉ាងនេះក៏ដោយ ក៏ខុមហ្វ្រែល នៅតែមានការបារម្ភអំពីភាពធ្ងន់ធ្ងរឡើងដែលមិនប្រែប្រួលចំពោះ បរិយាកាសអសន្តិសុខនាពេលយុទ្ធនាការឃោសនាបោះឆ្នោតចេះតែបន្ត ជាពិសេសបន្ទាប់ពីការលបបាញ់សម្លាប់លើលោក **ឃឹម សំបូរ** អ្នកយកព័ត៌មានដែលជាប់ពាក់ពន្ធ័នឹងគណបក្សសមរង្ស៊ី និងកូនប្រុសរបស់លោក កាលពីថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០០៨។

*ករណីឃាតកម្ម*

ខេត្តរតនគីរី ក្រុងព្រះសីហនុ ខេត្តឧត្តរមានជ័យ ក្រុងប៉ៃលិន និងខេត្តកំពត ។

***ការបង្កើនចំនួនកងទ័ពនៅតំបន់ប្រាសាទព្រះវិហារ***

ការដាក់ពង្រាយកងទ័ពកម្ពុជា និងកងយោធាថៃ ទៅកាន់តំបន់ជុំវិញប្រាសាទព្រះវិហារ បានចាប់ផ្តើមកាលពី ថ្ងៃ ទី១៥ កក្កដា ២០០៨ មួយសប្តាហ៍ក្រោយពេលប្រាសាទព្រះវិហារត្រូវបានចុះឈ្មោះជាសម្បត្តិបេតិកភណ្ឌពិភពលោក ។ ការដាក់ពង្រាយដោយទាហានឈុតខ្មៅថៃ បានទន្ទ្រានលើតំបន់ជុំវិញបរិវេណវត្ត ដែលមានទីតាំងនៅក្បែរប្រាសាទ ព្រះវិហារ។ ស្ថានភាពកាន់តែអាក្រក់នៅពេលដែលចំនួននៃទាហានខ្មែរ និងថៃបន្តកើនឡើង។ កិច្ចប្រជុំ រវាងភាគីទាំងពីរ ដើម្បីដោះស្រាយបញ្ហាការដកចេញនៃយោធាដែលបានប្រព្រឹត្តទៅនៅប្រទេសថៃកាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៨។

ថ្ងៃទី ២៦ កក្កដា ២០០៨ ជាថ្ងៃស្ងប់ស្ងាត់មួយ ដែលបានផ្តល់ឱ្យនៅក្នុងរយៈពេលនៃការបោះឆ្នោត ជាពេលផ្លូវការដែលមិនមានយុទ្ធនាការ ឬសកម្មភាពនយោបាយពាក់ពន្ធ័នឹងការបោះឆ្នោតបានកើតឡើង។ វាគឺជាពេលមួយដែលអ្នកបោះឆ្នោតសញ្ជឹងគិតមុនពេលពួកគេបោះឆ្នោត ។

ខុមហ្វ្រែល បានធ្វើការលើកសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ គ.ជ.ប និងអាជ្ញាធរដែលពាក់ព័ន្ធនឹងការបោះឆ្នោត ដែលបានធ្វើឱ្យដំណើរការបោះឆ្នោតប្រកបដោយភាពស្ងប់ស្ងាត់ ។ ការហាមប្រាមលើការលក់គ្រឿងស្រវឹង នៅថ្ងៃស (ទី២៦ កក្កដា) បានអនុវត្តប្រកបដោយប្រសិទ្ធភាព ។

ទោះបីជាយ៉ាងណា តាមរយៈការសង្កេតបានរកឃើញថា គណបក្សនយោបាយបានព្យាយាមទិញអ្នកបោះឆ្នោតខ្លះ ដោយការផ្តល់អំណោយ ថវិកា ដឹកជញ្ជូនកម្មករ និងអ្នកបោះឆ្នោតពីភ្នំពេញ ទៅកាន់ខេត្តក្រុងមួយចំនួន ដូចជា ខេត្ត ស្វាយរៀង ខេត្តកំពង់ចាម ។ល។ គណបក្សនយោបាយបានចែកអំណោយទៅដល់អ្នកបោះឆ្នោត ជាពិសេសនៅឃុំ ចំប៉ី ស្រុកអង្គរជ័យ ខេត្តកំពត និងនៅក្នុងឃុំកំពង់រោទិ៍ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ បន្ថែមពីនេះទៀត មានកងកម្លាំងប្រដាប់អាវុធជាច្រើននាក់ បានត្រូវគេបញ្ជូនឱ្យទៅបិទវិទ្យុមហានគរ អេហ្វ អឹម ៩៣.៥ ម៉េកាហឺត នៅពេលវេលាអធ្រាត្រ (ប្រហែលម៉ោង ២៣:០០ កាលពីថ្ងៃទី ២៦ ខែកក្កដា)។ វិទ្យុត្រូវបានបញ្ជាឱ្យបិទ ដោយក្រសួងព័ត៌មាន ដោយគ្មានការជូនដំណឹងជាលិខិតលាយលក្ខណ៍អក្សរ ឬប្រកាស (សេចក្តីបង្គាប់) ពីក្រសួង ។ ក្រសួងព័ត៌មានបានចេញ ប្រកាសមួយដកហូតអាជ្ញាប័ណ្ណផ្សព្វផ្សាយពីវិទ្យុ អេហ្វ អឹម ៩៣.៥ ម៉េកាហឺត នៅថ្ងៃទី ២៧ កក្កដា ២០០៨ ដោយអាស្រ័យហេតុផលថា ស្ថានីយ៍នោះបានរំលោភលើការអប់រំរបស់ក្រសួង និងការណែនាំរបស់គ.ជ.ប ដែលបានស្នើឱ្យក្រសួង ធ្វើអន្តរាគមន៍ ។

***ឈ្មោះអ្នកបោះឆ្នោតបានត្រូវគេថែមទៅក្នុងបញ្ជីជាច្រើន ក្រោយមានបញ្ជីជាផ្លូវការ***

មានករណីជាច្រើននៃឈ្មោះអ្នកបោះឆ្នោតដែលត្រូវបានគេថែមទៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត ដែលត្រូវបានប្រកាសជាផ្លូវការ កាលពីថ្ងៃទី ២៩ ឧសភា ២០០៨ ។ ទោះ បីជាយ៉ាងណា កាលពីថ្ងៃទី ៤ មេសា ២០០៨ គ.ជ.ប បាន សម្រេចបញ្ចូលឈ្មោះអ្នកបោះឆ្នោត ៣២១ នាក់ ថ្ងៃទី ២៩ ឧសភា ២០០៨ គ.ជ.ប បានបន្ថែមឈ្មោះផ្សេងទៀតចំនួន ១១៣៨ នាក់ ទៅក្នុងបញ្ជី។ យោងតាម គ.ជ.ប ការបន្ថែម ឈ្មោះអ្នកបោះឆ្នោតនេះ ពីព្រោះស្មៀនឃុំ ឬអាជ្ញាធរ ខកខានមិនបានបញ្ជូនឈ្មោះទាំងនោះទៅឱ្យ គ.ជ.ប ទាន់ពេលដើម្បីបញ្ចូលទៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតផ្លូវការ ។

***សរុបតួលេខ***

បញ្ជីឈ្មោះអ្នកបោះឆ្នោតផ្លូវការសម្រាប់ឆ្នាំ២០០៨ បានបង្ហាញថា មាន ៨.១២៤.០៩២ អ្នកដែលមានសិទ្ធិទៅបោះឆ្នោត។ មាន៩១១.៨៨១ អ្នកបោះឆ្នោតដែលបានចុះឈ្មោះថ្មីនៅក្នុងឆ្នាំ២០០៧ ដែលហួសពីការប៉ាន់ប្រមាណទុករបស់គ.ជ.ប ដែលមាន ៦៨២.៤៥៩ ដល់ទៅ ២៣០.០០០។ ទោះបីជាយ៉ាងណា ការអង្កេតការណ៍បានរកឃើញ ចំនួនមួយ ដ៏ខ្ពស់នៃអ្នកបោះឆ្នោតថ្មី ដែលមិនបានចុះឈ្មោះនៅលើជម្លោះដីធ្លី ឬនៅក្នុងការបណ្តេញចេញពីដី។

ការចុះឈ្មោះអ្នកបោះឆ្នោតជាលើកទី ២ ដែលបានជម្រះបញ្ជីដោយ និង បានលាត

ត្រូវជាងឱ្យដឹងថា អ្នកបោះឆ្នោតច្រើនជាង ៥៧.០០០ នាក់ (០.៧% នៃបញ្ជី) ត្រូវបានគេលុបដោយមិន ត្រឹមត្រូវ។[៦] ខុមហ្វ្រែលបានរកឃើញថា គ.ជ.ប បានលុបឈ្មោះអ្នកបោះឆ្នោតប្រហែលជា ៥៨០.០០០ នាក់ ពីបញ្ជីអ្នកបោះឆ្នោត។

គ.ជ.ប បានថ្លែងថា គ.ជ.ប បានអង្កេតលើភាពមិនប្រក្រតីខ្លះ នៅក្នុងវិធីដែលការជម្រះបញ្ជីត្រូវបាន ដឹកនាំធ្វើ ប៉ុន្តែបានទទួលស្គាល់ថាអាចមានអ្នកបោះឆ្នោតមួយចំនួនតូច ដែលមានឈ្មោះមិនត្រឹមត្រូវ ប៉ុន្តែគ.ជ.បមិនមានចេតនា ក្នុងការលុបឈ្មោះចោលពីបញ្ជីអ្នកបោះឆ្នោតទេ។ គ.ជ.ប បានថ្លែងទៀតថា គ.ជ.ប បានកំពុងបន្តស្វែងរកវិធីផ្សេងទៀត ដើម្បីធ្វើឱ្យប្រសើរឡើងនូវនីតិវិធី និងមានក្តីសង្ឃឹមយ៉ាងខ្លាំងថា អ្នកបោះឆ្នោតដែលមានឈ្មោះត្រូវបានគេលុបចោលនឹងមកចុះឈ្មោះជាថ្មីម្តងទៀត ក្នុងពេលចុះបច្ចុប្បន្នភាពប្រចាំឆ្នាំ២០០៨នៃបញ្ជីឈ្មោះអ្នកបោះឆ្នោត[៧]។

## *ការច្រានចោលនូវបេក្ខជនឈរឈ្មោះ*

យោងតាមមាត្រា ៣៨ (ថ្មី) នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បេក្ខជនដែលឈរឈ្មោះបោះឆ្នោត ត្រូវតម្រូវឱ្យមានការអះអាងពីការចុះឈ្មោះរបស់ពួកគេ ដោយអាជ្ញាធរឃុំ/សង្កាត់ដែលពាក់ព័ន្ធ ។ មានបញ្ហាមួយក្នុង ចំណោមបញ្ហាជាច្រើនដែលបណ្តាលឱ្យមានការលំបាកបំផុតសម្រាប់បេក្ខជនបញ្ចប់នូវទម្រង់ពាក្យសុំចុះឈ្មោះជាបេក្ខជន។

បេក្ខជនមកពីគណបក្សយ៉ាងតិច ៥ បានរៀបរាប់ពីការលំបាកដែលពួកគេបានប្រឈម ទាក់ទងនឹងប្រធានឃុំ និងក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលរើសអើងប្រឆាំងពួកគេ និងពន្យារនូវការបញ្ជាក់ការចុះឈ្មោះ។ យ៉ាងណាក៏ដោយ ការអង្កេត មិនបានរកឃើញករណីណាមួយដែលជាបញ្ហាអាចបណ្តាលឱ្យអ្នកដាក់ពាក្យសុំ បានខកខានក្នុងការចុះឈ្មោះពួកគេជាមួយ នឹង គ.ជ.ប និងមិនមានបណ្តឹងទៅ គ.ជ.ប ពីបញ្ហានេះទេ។

កាលពីថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០០៨ គណបក្សនយោបាយចំនួន ១១ ត្រូវបានចុះឈ្មោះជាផ្លូវការនៅ គ.ជ.ប។ គណបក្សសង្គមខ្មែរនិយម ត្រូវបានច្រានចោលដោយ គ.ជ.ប យោងតាមប្រតិទិនរបស់ខ្លួន។ គ.ជ.ប ត្រូវតែបែងចែកទៅឱ្យ ការិយាល័យគណៈកម្មការខេត្ត/ក្រុងរៀបចំការបោះឆ្នោត គខ/កប ដើម្បីបិទផ្សាយបញ្ជីឈ្មោះបេក្ខជនគណបក្សនយោបាយ នៅគខ/កប និងតាមមណ្ឌលខេត្ត/ក្រុង កាលពីថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០០៨ តែយ៉ាងនេះក៏ដោយ ក៏មានប្រជាពលរដ្ឋ តិចតួចណាស់ដែលបានទៅមើលបញ្ជីឈ្មោះនេះ។

នៅពេលកែប្រែបញ្ជីឈ្មោះបេក្ខជនតំណាងរាស្ត្រឡើងវិញជាលើកចុងក្រោយ បេក្ខជនចំនួន ៩៩ នាក់ ត្រូវបានច្រានចោល (ស្មើនឹង ៤%) ពីបេក្ខជនទាំង ២.៤៧៨ នាក់ ដែលត្រូវបានគេរកឃើញថា មិនមានឈ្មោះនៅក្នុងបញ្ជីអ្នក បោះឆ្នោត។ បេក្ខជនដែលត្រូវបានគេច្រានចោលខ្លះ ធ្លាប់បានបោះឆ្នោតនៅពេលបោះឆ្នោតអាណត្តិមុន ជាពិសេសការ បោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ នៅក្នុងឆ្នាំ២០០៧ បេក្ខជនខ្លះមានឈ្មោះពួកគេនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតឆ្នាំ ២០០៦ ប៉ុន្តែមិនបានលុបពីបញ្ជីឈ្មោះអ្នកបោះឆ្នោតជាផ្លូវការចុងក្រោយ។ បេក្ខជនដទៃទៀត មានកំហុសទិន្នន័យ បន្ទាប់បន្សំ ។ មន្ត្រី គ.ជ.ប និងក្រុមប្រឹក្សាឃុំ/សង្កាត់ បានបន្ទោសគ្នាទៅវិញទៅមកទៅលើបញ្ហានៃការបញ្ជាក់ឈ្មោះ បេក្ខជន នេះ ក្រុមប្រឹក្សាឃុំ/សង្កាត់ខ្លះ បានអះអាងថា ពួកគេបានចេញប្រកាសបញ្ជាក់បេក្ខជន ដោយពឹងផ្អែកទៅ លើ បញ្ជីអ្នកបោះ ឆ្នោតចាស់ ពីព្រោះ គ.ជ.ប មិនទាន់បានបញ្ជូននូវបញ្ជីផ្លូវការចុងក្រោយទៅឱ្យពួកគេ។ មន្ត្រី គ.ជ.ប បាន រិះគន់ក្រុម ប្រឹក្សាឃុំ/សង្កាត់សម្រាប់ការធ្វេសប្រហែសនៅក្នុងការងារពួកគេដែលនាំឱ្យមានការបញ្ជាក់ដែលភាន់ច្រឡំ ។

យ៉ាងណាក៏ដោយ គ.ជ.ប បានទទួលខុសត្រូវសម្រាប់ការបាត់ឈ្មោះពីបញ្ជីអ្នកបោះឆ្នោតផ្លូវការ ដូចជាមានករណី បេក្ខជនមកពីគណបក្សនរោត្តមរណឫទ្ធិ គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសង្គមខ្មែរនិយម ដែលមានបេក្ខជនយ៉ាងហោចណាស់ ៤០នាក់ ដែលបានបញ្ជាក់ឈ្មោះដោយមន្ត្រីឃុំ/សង្កាត់ ថាមានឈ្មោះនៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោត ដែល ពួកគេបានពិនិត្យដោយ គ.ជ.ប និងមិនបានរកឃើញនៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោតផ្លូវការចុងក្រោយ ដែលតម្រូវឱ្យមន្ត្រី ឃុំ/សង្កាត់ត្រូវកែតម្រូវនូវរបាយការណ៍របស់ពួកគេ ។

សិទ្ធិរបស់ គ.ជ.ប ដើម្បីបដិសេធន៍សេចក្តីប្រកាសអះអាងបញ្ជាក់ពីឈ្មោះបេក្ខជននៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោត ដែលចេញដោយអាជ្ញាធរឃុំ/សង្កាត់គឺមិនមានចែងនៅក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ ហេតុដូចនេះ គ.ជ.ប មិនមាន

---

៦ សេចក្តីថ្លែងការណ៍រួមរបស់ និកហ្វិច ខុមហ្វ្រែល កាស និង អិនឌីអាយ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៨

៧ ការឆ្លើយតបរបស់ គ.ជ.ប ដល់ អិនឌីអាយ ចំពោះលទ្ធផលនៃការធ្វើសោវនកម្មបញ្ជីឈ្មោះអ្នកបោះឆ្នោតលើកទី២ ចុះថ្ងៃទី៧ ខែកក្កដា ២០០៨

អំណាចផ្នែកច្បាប់ដើម្បីនឹងទាត់ចោលសេចក្ដីបញ្ជាក់អះអាងឡើយ។ ទង្វើនេះ នាំឱ្យបេក្ខជន ៩៩ នាក់ បានបាត់បង់សិទ្ធិរបស់ពួកគេដើម្បីឈរឈ្មោះឱ្យគេបោះឆ្នោត ហើយគណបក្សនយោបាយមួយ មិនអាចចូលរួមនៅក្នុងការបោះឆ្នោត គឺគណបក្សសង្គមខ្មែរនិយម។

គណបក្សសង្គមខ្មែរនិយម បានចុះឈ្មោះនូវបេក្ខជនរបស់ខ្លួន (១០២ បេក្ខជនពេញសិទ្ធិ និង ១០៩ បេក្ខជនបំរុង) ជាមួយនឹង គ.ជ.ប នៅក្នុង ២៣ មណ្ឌលបោះឆ្នោត ដើម្បីចូលរួមនៅក្នុងការបោះឆ្នោតសភាជាតិសម្រាប់អាណត្តិទី ៤។ គ.ជ.ប បានបដិសេធនឹងបេក្ខជន ២៥ នាក់ ដែលមិនបានរកឈ្មោះឃើញនៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោតផ្លូវការ ។

## ការបែងចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត

ការបែងចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត បានចាប់ផ្ដើមពីថ្ងៃទី ៥ ដល់ថ្ងៃទី ២៥ មិថុនា ២០០៨ មានភាពមិន ប្រក្រតីជាច្រើនត្រូវបានអង្កេតឃើញ។ គណបក្សនយោបាយខ្លះបានស្នើឱ្យគ.ជ.ប ដើម្បីអនុញ្ញាតឱ្យសកម្មជនរបស់ពួកគេ ចូលរួមនៅក្នុង



*រូបប័ណ្ណព័ត៌មានដែលចែកជូនដល់ពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត*

ផលប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតព្រមទាំងអ្នកដែលទៅបោះឆ្នោត ឬមិនទៅដែល មានចំនួនអ្នកបោះឆ្នោតយ៉ាងខ្ពស់បានកំពុងទៅស្ថានីយ៍បោះឆ្នោត ។

២-នៅក្នុងការបោះឆ្នោតមុនៗ មន្ត្រីរាជការស៊ីវិល និងអាជ្ញាធរមូលដ្ឋានមានវត្តមាននៅជុំវិញស្ថានីយ៍បោះឆ្នោត

៣-មានភាពមិនប្រក្រតី និងបណ្តឹងពាក់ព័ន្ធនឹងមន្ត្រីឃុំដែលមិនបានគោរពតាមបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត ឬសេចក្តីណែនាំរបស់គ.ជ.ប ពាក់ព័ន្ធនឹងការចេញទម្រង់ ១០១៨។ បញ្ហាទាំងនេះអាចនឹងប៉ះពាល់ដល់ ការសម្រេចចិត្ត របស់អ្នកបោះឆ្នោត និងទិន្នន័យនៃការបោះឆ្នោត។

## ការរាប់សន្លឹកឆ្នោត និងការសរុបលទ្ធផលបោះឆ្នោត

ក្រោយពីដំណើរការបោះឆ្នោតបានបញ្ចប់នៅម៉ោង ១៥:០០ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ ខុមហ្វ្រែល នៅតែបន្តធ្វើការសង្កេតលើដំណើរការសន្តិសុខនៃសន្លឹកឆ្នោតដោយមន្ត្រីបោះឆ្នោត និងបានរកឃើញភាពមិនប្រក្រតីដូចខាងក្រោម:



សកម្មភាពរាប់សន្លឹកឆ្នោតនៅថ្ងៃបោះឆ្នោត

- ១៩ករណី នៃការអនុញ្ញាតឱ្យមនុស្សជាច្រើនដែលមិនមានកាតព្វកិច្ចចេញចូលក្នុងស្ថានីយបោះឆ្នោត នៅកំឡុងពេលដំណើរការបិទមាន កើតឡើងនៅក្នុងខេត្តបន្ទាយមានជ័យ ខេត្តកំពង់ឆ្នាំង រាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តតាកែវ ។
- ៤ ករណី នៃការមិនដាក់គ្របទៅលើគម្របប្រហោងសម្រាប់ស៊កសន្លឹកឆ្នោត ឬមិនបានចាក់សោរឃ្លុំស្បោងធំ ដែលបានប្រើ សម្រាប់ខ្ចប់ប្រអប់បោះឆ្នោត កើតមាននៅក្នុងខេត្តបាត់ដំបង និងខេត្តព្រៃវែង ។
- ២២ករណី នៃការរំខានដំណើរការរាប់សន្លឹកឆ្នោត កើតមាននៅក្នុងខេត្តបន្ទាយមានជ័យ ខេត្តកំពង់ឆ្នាំង ខេត្តព្រៃវែង រាជធានីភ្នំពេញ និងខេត្តតាកែវ ។

ក្នុងកំឡុងពេលកំពុងដំណើរការរាប់សន្លឹកឆ្នោតខុមហ្វ្រែល បានអង្កេតឃើញមន្ត្រីរាប់សន្លឹកឆ្នោតនៅស្ថានីយបោះឆ្នោតខ្លះមិនបានអនុលោមតាមបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត ឬគោលការណ៍ណែនាំរបស់គ.ជ.ប ។ ជាលទ្ធផល ឃើញមានភាពមិនប្រក្រតីដូចខាងក្រោម :

- ១៣ ករណី នៃការពន្យារពេលដំណើរការរាប់សន្លឹកឆ្នោត នៅក្នុងស្ថានីយបោះឆ្នោត កើតមាននៅក្នុងខេត្ត បន្ទាយមានជ័យ ខេត្តកំពង់ចាម ខេត្តកំពង់ធំ រាជធានីភ្នំពេញ ខេត្តព្រៃវែង និងខេត្តតាកែវ។
- យ៉ាងហោចណាស់ ២ ករណី នៃការមិនអនុញ្ញាតឱ្យអ្នកអង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយចូលរួមសង្កេតដំណើរការរាប់សន្លឹកឆ្នោត កើតមាននៅក្នុងខេត្តព្រៃវែង ។
- ២ ករណី នៃការមិនអនុញ្ញាតឱ្យអ្នកអង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយ ចូលសង្កេតលើសោរឃ្លុំបិទនៅលើប្រអប់ឆ្នោត មុនពេលបិទគម្របគ្របលើប្រអប់ឆ្នោត កើតឡើងនៅក្នុងខេត្តកំពង់ចាម ។
- ២៧ ករណី នៃការរាប់សន្លឹកឆ្នោតរហ័សពេក ឬមិនបានបង្ហាញឱ្យច្បាស់លាស់នូវក្រដាស សន្លឹកឆ្នោតទៅកាន់អ្នកអង្កេតការណ៍ ឬភ្នាក់ងារគណបក្សនយោបាយ កើតឡើងនៅក្នុងខេត្តបន្ទាយមានជ័យ ខេត្តកំពង់ចាម ខេត្តក្រចេះ រាជធានីភ្នំពេញ ខេត្តព្រះវិហារ ខេត្តព្រៃវែង ខេត្តស្វាយរៀង និងខេត្តតាកែវ។
- ១៦ ករណី នៃការប្រកាសលទ្ធផលបោះឆ្នោតមិនត្រឹមត្រូវ កើតឡើងជាពិសេសនៅក្នុងខេត្តតាកែវ រាជធានី ភ្នំពេញនិងខេត្តកំពង់ធំ
- ៥ ករណី នៃការទទួលយកសន្លឹកឆ្នោតបានការ និងបដិសេធសន្លឹកឆ្នោតមិនបានការ តែមិនបានបង្ហាញសន្លឹក ឆ្នោតទាំងនោះទៅដល់អ្នកសង្កេតការណ៍ ឬភ្នាក់ងារគណបក្សនយោបាយ កើតមាននៅក្នុងខេត្តកំពង់ឆ្នាំង និងរាជធានីភ្នំពេញ
- ៤ ករណី នៃការកង្វះខាតសម្ភារៈបោះឆ្នោតសំខាន់ៗ ដែលបានបង្អាក់នូវដំណើរការរាប់សន្លឹកឆ្នោត កើតមាននៅក្នុងខេត្តបន្ទាយមានជ័យ និងរាជធានីភ្នំពេញ ។

## ការជ្រើសរើសមន្ត្រីអាជ្ញាធរបោះឆ្នោត និងការបំពេញភារកិច្ច



*កិច្ចប្រជុំរបស់ គ.ជ.ប ជាមួយភាគីពាក់ព័ន្ធការបោះឆ្នោត*

មន្ត្រីភាគច្រើនដែលកំពុងបំពេញការងារនៅ គណៈកម្មការខេត្ត-ក្រុងរៀបចំការបោះឆ្នោត (គខ/កប) និង គណៈកម្មការឃុំ-សង្កាត់រៀបចំការបោះឆ្នោត (គឃ/សប) ជាអតីតមន្ត្រី ដែលមានបទពិសោធន៏នៅក្នុងការបោះឆ្នោតមុនៗមិនសូវមានមន្ត្រីថ្មីៗទេ។ បន្ថែមពីនេះ ភាគច្រើននៃប្រធាន និងសមាជិករបស់ គខ/កប និង គឃ/សប ជ្រើសរើស ចេញពីនាយកដ្ឋានខេត្ត/ក្រុង។ នៅក្នុងអតីតកាល សមាជិក គខ/កប និង គឃ/សប ចាស់ៗត្រូវបានរងការចោទប្រកាន់ ថាមានភាពលម្អៀងទៅរកគណបក្សប្រជាជនកម្ពុជា និងក្នុងករណីខ្លះ វិធីដែលពួកគេបំពេញតួនាទីរបស់ខ្លួននៅក្នុងការបោះឆ្នោតមុនៗ គឺបំពេញចិត្តគណបក្សនោះ។ លើកនេះ មានពាក្យចចាមអារាមថា នៅក្នុងដំណើរ ការជ្រើសរើសបុគ្គលិក សម្រាប់គណៈកម្មការស្ថានីយ៍បោះឆ្នោត និងរាប់សន្លឹកឆ្នោត នៅក្នុងស្ថានីយ៍បោះឆ្នោតខ្លះ ថវិកាត្រូវបានផ្តល់ជាសំណូក ដើម្បីបានទទួលមុខងារពិតប្រាកដ។ ជាងនេះទៅទៀត យ៉ាងហោចណាស់ មានបណ្តឹង ៤ ដែលបានប្តឹងដោយ គណបក្សនយោបាយ (៣ ករណី ដោយគណបក្សសមរង្ស៊ី និង១ករណីដោយគណបក្សសិទ្ធិមនុស្ស) ចោទប្រកាន់មន្ត្រី គឃ/សប ថាបានបំពេញមុខងារមានភាពលម្អៀង និងបំពារបំពានទៅលើនីតិវិធី និងបទបញ្ជា។ មានករណី មួយ គឃ/សប នៅក្នុងឃុំ ស្រុកបានឡុង ខេត្តរតនគីរី បានទាមទារឱ្យគណបក្សសមរង្ស៊ីរើស្លាកគណបក្សចេញ ដែលបានដាក់តាំង នៅចម្ងាយប្រហែល ២០០ ម៉ែត្រ ពីសាលាបុរីចំការប៊ុន ដែលត្រូវបានជ្រើសរើសជាស្ថានីយ៍ សម្រាប់ អាណត្តិ ទី ៤ ដែលបានមកដល់។ មិនមានការស្នើទាមទារដោយ គឃ/សប ឱ្យគណបក្សប្រជាជនកម្ពុជា រើស្លាកគណបក្សដែលបានដាក់នៅ ចម្ងាយប្រហែល ៤0ម៉ែត្រ ពីស្ថានីយ៍បោះឆ្នោតមួយនៅក្នុងឃុំយក្សឡោម នៃស្រុកបានលុង ។

គ.ជ.ប បានចាត់ចែង និងបំពេញតួនាទី និងកាតព្វកិច្ចដែលអនុលោមតាមប្រតិទិនបោះឆ្នោត។ យោងតាម មាត្រា ១៦ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គ.ជ.ប នឹងទទួលខុសត្រូវសម្រាប់រៀបចំផែនការរៀបចំ និងចាត់ចែងការបោះឆ្នោតទូទាំងប្រទេស និងមានសិទ្ធិពេញលេញ ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ ខុមហ្វ្រែលរកឃើញថា ភាគច្រើននៃការបំពេញមុខងាររបស់គ.ជ.ប នៃកាតព្វកិច្ច និងកិច្ចការងារ ទាំង ២៧ របស់ខ្លួន (មើលតារាង ខាងក្រោម)បានត្រឹមមធ្យម។ ការបំពេញមុខងារជាវិជ្ជមាន បានឃើញនៅក្នុងការទំនាក់ទំនងជា មួយនឹងការរៀបចំផែនការ ចាត់ចែង និងគ្រប់គ្រងមើលថែរក្សាការបោះឆ្នោតដូចជានៅក្នុងការ :

១- រៀបចំគម្រោងផែនការការងារ ថវិកា និងសម្ភារៈសម្រាប់ការបោះឆ្នោត និងការផ្សព្វផ្សាយកាលបរិច្ឆេទបោះឆ្នោត
២- ស្នើ និងបង្ខំឱ្យអនុវត្តវិធានការនានា ដើម្បីថែរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈនៅពេលបោះឆ្នោត
៣- ចេញនូវការសំរេចចិត្តទាក់ទងនឹងទីតាំងស្ថានីយ៍ចុះឈ្មោះ និងបោះឆ្នោត
៤- ផលិតនូវសម្ភារៈបោះឆ្នោត និងឧបករណ៏សម្រាប់បោះឆ្នោត
៥- ផលិត និងផ្សព្វផ្សាយ សៀវភៅដែលបានបោះពុម្ពផ្សាយស្តីពីការបោះឆ្នោត
៦- ជំរុញឱ្យសាធារណៈជនបានដឹងពីដំណើរការនៃការបោះឆ្នោតតាមរយៈអប់រំអ្នកបោះឆ្នោត និងកម្មវិធីផ្សព្វផ្សាយជាសាធារណៈ និងវិធីផ្សេងទៀត
៧- រៀបចំកម្មវិធី និងហ្វឹកហាត់សម្រាប់មន្ត្រីបោះឆ្នោត

ទោះបីជាយ៉ាងណា ការសង្កេតរបស់ខុមហ្វ្រែល នៅរកឃើញចំនុចខ្សោយជាច្រើនទៀត និងអំពើរំលោភបំពាន នឹងច្បាប់បោះឆ្នោត នៅក្នុងការបំពេញមុខងាររបស់មន្ត្រីគ.ជ.ប ចំពោះកាតព្វកិច្ចទាំង ២៧ របស់ខ្លួន ។

១- រៀបចំបញ្ជីឈ្មោះ និងសៀវភៅបញ្ជីឈ្មោះអ្នកបោះឆ្នោត ត្រួតពិនិត្យធនធានហិរញ្ញវត្ថុ និងការចំណាយសម្រាប់បេក្ខជន និងគណបក្សនយោបាយ នៅក្នុងពេលឃោសនាបោះឆ្នោត
២- បដិសេធប័ណ្ណបញ្ជាក់បេក្ខជនបោះឆ្នោតដែលមានឈ្មោះពួកគេនៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោត (ចេញដោយអាជ្ញាធរឃុំ/សង្កាត់) ដែលហួសពីសមត្ថកិច្ចរបស់ គ.ជ.ប
៣- ភាពបរាជ័យក្នុងការខកខានបែងចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតទៅដល់អ្នកបោះឆ្នោតទាំងអស់
៤- ការបញ្ចូលគ្នាដោយខុសច្បាប់នៃលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ដោយ គឃ/សប

៥- អន្តរាគមន៍ដែលគ្មានប្រសិទ្ធភាពរបស់ គ.ជ.ប ដែលពាក់ព័ន្ធនឹងប្រព័ន្ធផ្សព្វផ្សាយឯកជន។ ភាគច្រើននៃប្រព័ន្ធផ្សព្វផ្សាយឯកជនមានលម្អៀងទៅរកគណបក្សប្រជាជនកម្ពុជាដែលកំពុងតែកាន់អំណាច និងមិនបានអនុវត្តតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងបទបញ្ជា នីតិវិធី និងគោលការណ៍ណែនាំរបស់គ.ជ.ប ។

តារាងខាងក្រោម និងវាយតម្លៃពីការបំពេញមុខងាររបស់ គ.ជ.ប នៅក្នុងទំនាក់ទំនងភារកិច្ចទាំង ២៧ របស់ខ្លួន និងកាតព្វកិច្ចសម្រាប់ការបោះឆ្នោតសភាជាតិ ២០០៨ ដោយខុមហ្វ្រែល ។

## អំឡុងពេលក្រោយការបោះឆ្នោត និងការផ្ទេរអំណាច : វិបត្តិនៃការបង្កើតសភាជាតិ

នៅពេលដឹងលទ្ធផលបោះឆ្នោតភ្លាម គណបក្ស ៤ រួមមាន គណបក្សសមរង្ស៊ី គណបក្សសិទ្ធិមនុស្ស គណបក្ស នរោត្តមរណឫទ្ធិ និងមន្ត្រីជាន់ខ្ពស់នៃគណបក្សហ៊្វុនស៊ិនប៉ិច បានបដិសេធនឹរួមគ្នានូវលទ្ធផលបោះឆ្នោតសភាជាតិ ថ្ងៃទី២៧ ខែកក្កដា ដោយលើកឡើងពីភាពមិនប្រក្រតីជាច្រើន ការប្រតិបត្តិដោយលួចបន្លំ និងខុសច្បាប់ ពាក់ព័ន្ធនឹងទម្រង់ ១០១៨ និងការលុបឈ្មោះអ្នកមានសិទ្ធិបោះឆ្នោតពីបញ្ជីឈ្មោះ អ្នកបោះឆ្នោត (ចំនួននៃអ្នកបោះឆ្នោតជាច្រើនដែលមិនអាចបោះឆ្នោតបាន)។ គណបក្សនយោបាយជាច្រើនបានចេញនូវ សេចក្តីថ្លែងការណ៍រួមគ្នាដែលអំពាវនាវឱ្យសហគមន៍ សាធារណៈជាតិ និងអន្តរជាតិមិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត។ គណបក្សទាំងនោះរើកញែកថា ដំណើរការនៃការបោះឆ្នោត មានលក្ខណៈបញ្ឆោត និងបានផ្តល់សម្ភារៈ ដោយគណបក្ស កំពុងកាន់អំណាច (គណបក្សប្រជាជនកម្ពុជា) និងគ.ជ.ប។ ក្រោយមកបន្តិច បានប្រកាសទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត ពីព្រោះគណបក្សនេះ ចង់ចូលរួមជាមួយរដ្ឋាភិបាលគណបក្សប្រជាជនកម្ពុជា។ គណបក្សនរោត្តមរណឫទ្ធិ បានប្រកាសថា អ្នកនាំពាក្យ គណបក្ស និងជានាយកខុទ្ទកាល័យ លោក (រិះគន់តតសំចៃ) ត្រូវបានជំនួសដោយ អគ្គលេខាធិការរង លោក ដែលគណបក្សទទួលស្គាល់ការបោះឆ្នោត និងលទ្ធផលបោះឆ្នោត ថាមានភាពសេរី និងត្រឹមត្រូវ ពីព្រោះ គណបក្សនេះចង់ឱ្យនាយករដ្ឋមន្ត្រីផ្តល់ភ្លើងខៀវឱ្យព្រះមហាក្សត្រ លើកលែងទោសដល់ព្រះអង្គម្ចាស់នរោត្តមរណឫទ្ធិ។ ប្រធានគណបក្ស នរោត្តមរណឫទ្ធិ ព្រះអង្គម្ចាស់ **នរោត្តមរណឫទ្ធិ** ដែលបានដាក់ព្រះកាយព្រះអង្គរស់នៅ និរទេសអស់ រយៈពេលជាង ២ ឆ្នាំ ដើម្បីគេចពីការដាក់គុកពីករណីវិវាទនៃការដាក់ទណ្ឌកម្ម បានត្រឡប់មកប្រទេសកម្ពុជាវិញកាល ពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៨ ។ នៅក្នុងខែតុលា ព្រះអង្គម្ចាស់បានសម្រេចលាចាកពីនយោបាយ និងបានប្រគល់ការគ្រប់គ្រងគណបក្សទៅឱ្យអនុប្រធានបក្សវិញ ។

អតីតអគ្គលេខាធិការគណបក្សសិទ្ធិមនុស្ស លោក បានផ្លាស់ប្តូរតួនាទីរបស់លោក និងបានក្លាយជាអនុប្រធានគណៈកម្មការវិន័យគណបក្សសិទ្ធិមនុស្សវិញ។ បន្ថែមពីនេះទៀត សមាជិកស្ថាបនិកសំខាន់មួយរូប និងជាអ្នកដឹកនាំទី ២ នៃគណបក្សសិទ្ធិមនុស្ស លោក បានចាកចោលគណបក្ស ហើយចូលរួមជាមួយនឹងគណបក្សកំពុងកាន់អំណាច គណបក្សប្រជាជនកម្ពុជា។

ទោះបីជាគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សនរោត្តមរណឫទ្ធិ បានសម្រេចចាកចេញពីសម្ព័ន្ធភាពអ្នកប្រឆាំង គណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្ស បានប្តេជ្ញាធ្វើពហិការចូលរួមពិធីបើកសភាជាតិ ដែលជាការសំខាន់ក្នុងការបង្កើតសភាជាតិ ទោះបីជាជម្រើសនៅតែមានសម្រាប់ការបង្កើតរដ្ឋាភិបាល។ មានជម្លោះនៅលើលទ្ធផលនៃការបោះឆ្នោត និងការបកស្រាយខុសគ្នាអំពីច្បាប់ដែលទាក់ទងនឹងសុពលភាពនៃសមាជិកសភាដែលបានជាប់ឆ្នោតថ្មី។ អ្នកតាក់តែងច្បាប់ គណបក្សប្រជាជនកម្ពុជា និងរដ្ឋាភិបាលបានពន្យល់ថា ប្រសិនបើគណបក្សប្រឆាំងធ្វើពលិការចូលរួមក្នុងពិធីស្បថចូលកាន់តំណែង និងសម័យប្រជុំលើកដំបូងនៃសភាជាតិថ្មី សមាជិកភាពសភាជាតិដែលបានជាប់ឆ្នោតថ្មីអាចនឹងគ្មានសុពលភាព នឹងនាំទៅរកការបាត់បង់អាសនៈសភាសម្រាប់គណបក្សទាំងនោះ។

មាត្រា ៧៦ នៃរដ្ឋធម្មនុញ្ញ និងក្រុមប្រឹក្សាធម្មនុញ្ញ នៃរដ្ឋដែលកំពុងកាន់អំណាចបានបញ្ញតិថា *"រដ្ឋសភាមានសមាជិកជាតំណាងរាស្ត្រ យ៉ាងតិច ១២០រូប"* នៅសម័យប្រជុំដំបូង ក្រោយការបោះឆ្នោតនីតិបញ្ញាតិ សភាជាតិដំបូង ត្រូវប្រកាសសុពលភាពនៃគ្រប់អាណត្តិសមាជិកទាំងអស់។ ហេតុដូចនេះ ប្រសិនបើគ្មានវត្តមាន សមាជិកបោះឆ្នោតយ៉ាង តិច ១២០ នៅសម័យប្រជុំទីមួយ វាមិនអាចដំណើរការបានសម្រាប់សភាជាតិដែលមានអំណាចធ្វើសេចក្តីសម្រេចចិត្ត ប្រកបដោយសុពលភាព រាប់បញ្ចូលការសម្រេចចិត្តដើម្បីប្រកាសសុពលភាពនៃគ្រប់សមាជិកទាំងអស់។

ប្រសិនបើគណបក្សប្រឆាំងបានធ្វើពហិការចូលរួមពិធីស្បថចូលកាន់តំណែង នៅក្នុងការប៉ុនប៉ងដាក់សម្ពាធលើ មាត្រា ៧៦ នៃរដ្ឋធម្មនុញ្ញ ពួកគេអាចប្រថុយនឹងការបាត់បង់អាសនៈសមាជិកសភារបស់ពួកគេ។ ប្រសិនបើ សភាជាតិថ្មី បង្កើតឡើង ដោយគ្មានការចូលរួមពីគណបក្សសមរង្ស៊ី ដែលឈ្នះបាន ២៦ អាសនៈ និងគណបក្សសិទ្ធិមនុស្ស ដែលឈ្នះ ៣ អាសនៈ សភាជាតិមិនអាចប្រព្រឹត្ត

ទៅត្រឹមត្រូវតាមច្បាប់ទេ ។ នាយករដ្ឋមន្ត្រី បាននិយាយថា "ប្រសិនបើ គណបក្សនយោបាយមិនបានចូលរួមនៅក្នុងការស្បថចូលកាន់តំណែង អាសនៈដែលបានឈ្នះដោយគណបក្ស សមរង្ស៊ី និង គណបក្សប្រឆាំងដទៃទៀត និងត្រូវបែងចែកទៅឱ្យគណបក្សដទៃ មានន័យថា គណបក្សប្រជាជនកម្ពុជា និងគណបក្ស ដទៃទៀតដែលអាចធ្វើបាន" [៨]។ យោងតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ពិសេសមាត្រា ១១៨ បញ្ញត្តិថា ២៩ អាសនៈរបស់គណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្ស ក្នុងចំណោមគណបក្សដទៃទៀតដែលជាតំណាង នៅសភាជាតិបានមកពីមូលដ្ឋាននៃចំនួនអាសនៈ និងសន្លឹកឆ្នោតដែលគណបក្សទទួលបានពីខេត្តផ្សេងៗ។ តាមតួលេខ មូលដ្ឋានដែលបានផ្តល់ដោយគណបក្សប្រជាជនកម្ពុជាផ្ទាល់ និងភាពរឹងមាំជាមួយនឹងប្រព័ន្ធសមាមាត្ររបស់យើងបានបង្ហាញនូវការបញ្ចូលគ្នាជាមួយនឹងរូបមន្ត ជាក់លាក់ណាស់សម្រាប់ការបែងចែកអាសនៈ គណបក្សប្រជាជនកម្ពុជាប្រមូល អាសនៈដែលបានបែងចែកទៅឱ្យគណបក្សប្រឆាំងមុនៗទាំងអស់។ រូបមន្តនេះអាចមាន ១១៩ អាសនៈ(៩៧%) សម្រាប់គណបក្សប្រជាជនកម្ពុជា ក្នុងចំណោមសមាជិកភាព ១២៣ នៃសភាជាតិ ។ គណបក្សប្រឆាំងមិនអាចបំពេញកាតព្វកិច្ច របស់ខ្លួនតំណាងឱ្យប្រជាពលរដ្ឋទាំង ១.៦ លាននាក់ ដែលបានបោះឆ្នោតគាំទ្រពួកគេប្រសិនបើមានករណីនេះ។

តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាមួយរូបបានព្រមានថា កិច្ចប្រជុំពេញអង្គនៃសភាជាតិ ដែលសមាជិកភាពថ្មី ត្រូវបានស្បថចូលកាន់តំណែងតាមរយៈសេចក្តីប្រកាសជាផ្លូវការនៃលទ្ធផលនៃការបោះឆ្នោតមិនអាចបញ្ឈប់ដោយចេតនា ពហិការរបស់គណបក្សប្រឆាំងពីរនោះទេ។ គណបក្សប្រជាជនកម្ពុជា អាចមើលទៅលើជម្រើសច្រើន សម្រាប់ការបង្កើត សភា រដ្ឋាភិបាល ទោះបីជាការបង្ខិតបង្ខំនៅក្នុងការបកស្រាយច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នៃការធ្វើពហិការនានានៃការចូលមកដល់ពិធីស្បថចូលកាន់តំណែងដោយគណបក្ស ២ ។

តំណាងរាស្ត្រគណបក្សប្រឆាំងបានវែកញែកថា ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាង រាស្ត្រមិនអាចធ្វើ វិសោធនកម្មប្រសិនបើមានការប៉ះពាល់ដល់ប្រព័ន្ធពហុបក្ស ឬរបបរាជានិយមអាស្រ័យធម្មនុញ្ញ ដែលជាគោលការណ៍ នៅក្នុងរដ្ឋធម្មនុញ្ញ។ នេះមានន័យថា សម្លេងភាគច្រើននៅក្នុងសភាប្រជាធិបតេយ្យ អាចធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ប៉ុន្តែមិនអាចរួមគំនិតក្បត់ក្នុងការធ្វើដូចនេះនៅពេលដែលប្រទេសស្ថិតនៅក្នុងភាពអាសន្ន ឬរួមគំនិតក្បត់ លប់បំបាត់ មាត្រា ៥១ ដែលការពារប្រជាធិបតេយ្យ ប្រព័ន្ធពហុបក្ស។

រហូតមកដល់ថ្ងៃទី ២៣ ខែកញ្ញា គណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្ស នៅតែអាចប្តេជ្ញាចិត្តធ្វើពហិការ ចូលរួមពិធីស្បថចូលកាន់តំណែង ដែលបានកំណត់ដោយព្រះមហាក្សត្រនៅថ្ងៃទី ២៤ កញ្ញា លើការពោលពីការបោះឆ្នោត ដែលអសុទ្ធចិត្ត ដោយគណបក្សកាន់អំណាច ទាមទារឱ្យមានពិធីដាច់ដោយឡែកនៅថ្ងៃ ២៥ កញ្ញា។ នៅក្នុងក្របខ័ណ្ឌ ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតថា នៅក្នុងកំឡុងពេល ៦០ ថ្ងៃនៃការបោះឆ្នោត គណបក្សនយោបាយអាចប្រារព្ធពិធីស្បថចូលកាន់តំណែងដោយឡែក ដើម្បីទទួលសមាជិកភាពសភាជាតិដោយស្របច្បាប់ ឬមានសុពលភាព ។



*ពិធីប្រកាសបដិសេធលទ្ធផលឆ្នោតរបស់គណបក្សប្រឆាំង*

ទោះបីជាយ៉ាងណា នៅនាទីចុងក្រោយកាលពីថ្ងៃទី ២៤ កញ្ញា គណបក្សសមរង្ស៊ីបានសម្រេចចូលរួមពិធីដោយ មិនមានការយល់ព្រមពីគណបក្សសិទ្ធិមនុស្ស។ គណបក្សសមរង្ស៊ីបានពន្យល់ថា នាយករដ្ឋមន្ត្រី (អនុប្រធានគណបក្សប្រជាជនកម្ពុជា) បានយល់ព្រមជាមួយនឹងលក្ខខណ្ឌអនុម័តជាបណ្តោះអាសន្នដែលទទួលស្គាល់ គណបក្សប្រឆាំង តាមច្បាប់ និងតួនាទីរបស់ពួកគេនៅ ក្នុងសភាជាតិ។ មិនដូចជានៅក្នុងឆ្នាំ ២០០៣ ដែលតំរូវសម្លេងភាគច្រើន ២ ភាគ ៣ សំរាប់អាណត្តិនេះ គណបក្សប្រជាជនកម្ពុជាមានចំនួនសមាជិកសភាច្រើនជាងគ្រប់គ្រាន់សមាជិកសភាជាតិ (គណបក្សនេះ ត្រូវការត្រឹមតែ ៥០% បូក ១សម្លេងបោះឆ្នោតភាគច្រើននៃសមាជិកសភាជាតិ តាមរយៈការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ) ដើម្បីអង្កេតរដ្ឋាភិបាល។ ជាមួយនឹង ៩០ អាសនៈសភាគណបក្សប្រជាជនកម្ពុជា អាចងាយស្រួលបង្កើតសម្លេងភាគច្រើន នៃអាសនៈ សរុបទាំង ១២៣ ដើម្បីធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ឬឈានដល់កែប្រែ កូរ៉ុម សម្រាប់ ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តនៅក្នុងការបង្កើតសភាជាតិថ្មី និងតែងតាំងនាយករដ្ឋមន្ត្រី និងគណៈរដ្ឋមន្ត្រី ។ ទោះបីជា យ៉ាងណា គណបក្សប្រជាជនកម្ពុជាបានសម្រេចប្រើការបោះឆ្នោតជាកញ្ចប់ សម្រាប់ការផ្តល់សេចក្តីទុកចិត្តលើការបង្កើតរដ្ឋាភិបាល និងអ្នកដឹកនាំសភាជាតិជាមួយគ្នា។ កាលពីថ្ងៃទី ២៥ កញ្ញា គណបក្សប្រឆាំង មានគណបក្សសិទ្ធិមនុស្ស និងគបណបក្ស

---

៨ ការដកស្រង់សម្តីសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៨ នៅឯព្រលានយន្តហោះអន្តរជាតិភ្នំពេញ

សមរង្ស៊ី មិនបានចូលរួមនៅក្នុងកិច្ចប្រជុំ និងទាត់ចោលការបោះឆ្នោតជាកញ្ចប់នេះ។ អ្នកជំនាញការខាងរដ្ឋធម្មនុញ្ញ បានបកស្រាយហេតុផលដែលច្រានចោលការបោះឆ្នោតជាកញ្ចប់នេះមានដូចខាងក្រោម :

១- សម័យប្រជុំសភា បានកាន់កាប់ដោយព្រឹទ្ធបុរសរបស់គណបក្សប្រជាជនកម្ពុជា សម្រាប់ការបោះឆ្នោតជា កញ្ចប់នេះ គឺនៅក្នុងការរំលោភបំពានលើមាត្រា ៨២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ការបោះឆ្នោតជាកញ្ចប់ មិនអាចអនុវត្តមុនការអនុវត្តនៃមាត្រា៨២នេះ ដែលបានបញ្ញត្តិថា "មុនចាប់ ផ្តើម ការងាររបស់ខ្លួន រដ្ឋសភាត្រូវសម្រេច លើ សុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងបោះឆ្នោត ដោយឡែក ដើម្បីជ្រើសរើសប្រធាន អនុប្រធាន និង សមាជិក នៃគណៈកម្មាធិការនានារបស់រដ្ឋសភា ដោយសម្លេងឆ្នោត ភាគច្រើន ៥០% ១"។

២- ការបោះឆ្នោតជាកញ្ចប់ គឺរំលោភបំពានមិនត្រឹមតែមាត្រា៨២ ថែមទាំងរំលោភបំពាន មាត្រា ១១៩ ថ្មី នៃរដ្ឋធម្មនុញ្ញផងដែរ។ វាគឺបានបញ្ជាក់នៅក្នុងមាត្រានេះថា "តាមសេចក្តីស្នើពីប្រធាន ដោយមានមតិឯកភាពពីអនុប្រធានទាំងពីរ នៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវិរជនមួយរូបក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សដែលឈ្នះឆ្នោតឱ្យបង្កើតរាជរដ្ឋាភិបាល។ វិរជនដែលត្រូវបានចាត់ចែងនេះនាំសហការីដែល ជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្សតំណាងរាស្ត្រក្នុងរដ្ឋសភា ដែលផ្គូរផ្គងឱ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល ទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា ។"

៣- ការបោះឆ្នោតជាកញ្ចប់មិនត្រឹមតែរំលោភបំពានលើរដ្ឋធម្មនុញ្ញ ថែមទាំងប្រឆាំងនឹងកម្រិតសីលធម៌ដែលសមាជិកសភាបានស្បថ។ សមាជិកសភាបានសន្យាជាឧឡារិក ដើម្បីនឹង "គោរពរដ្ឋធម្មនុញ្ញ" នៅមុខព្រះភក្ត្ររបស់ព្រះមហាក្សត្រ ព្រះសង្ឃរាជ និងទេវតាថែរក្សាការពាររាជបល្ល័ង្ក ។

ជាលទ្ធផលនៃការបោះឆ្នោតជាកញ្ចប់ គណបក្សប្រជាជនកម្ពុជា ត្រួតត្រាគ្រប់មុខតំណែងជាប្រធានគណៈកម្មាធិការសភាជាតិ និងអនុប្រធានទាំងអស់ និងគ្រប់មន្ទីរនៃរដ្ឋាភិបាលទាំងអស់។ តំណាងរាស្ត្រដែលបានបោះឆ្នោតទៅ សភាជាតិមកពីគណបក្សប្រឆាំង មិនត្រូវបានគេជ្រើសរើសធ្វើជាប្រធានគណៈកម្មាធិការជំនាញនៃសភាជាតិ ឬសមាជិកនៃគណៈកម្មាធិការទេ។ ចំនួនសមាជិករដ្ឋាភិបាលបានកើនឡើងច្រើនជាង ៣៥ % បើប្រៀបធៀបនឹងអាណត្តិមុន ដែល មានប្រហែលជា ២៥០ រូប កាន់កាប់មុខងារឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ ។ ការចែករំលែក អំណាចនៅក្នុងរចនាសម្ព័ន្ធភាពជាអ្នកដឹកនាំសភាជាតិ បានបង្ហាញនូវកង្វល់ថា នៅក្នុងអតីតកាល មិនមានក្របខណ្ឌច្បាប់ ច្បាស់លាស់ដែលបានបកស្រាយពីបញ្ហានេះ លើកលែងតែការអនុវត្តដែលឈរលើគោលការណ៍សម្របសម្រួលនយោបាយក្នុង ចំណោមឥស្សរៈជននយោបាយ។ ការបង្កើតនូវគណៈកម្មាធិការសភាជាតិដែលមិនមានសមាសភាពដើម្បីធានាតុល្យភាព អំណាចដ៏សមរម្យរវាងគណបក្ស កំពុងកាន់អំណាច និងគណបក្សប្រឆាំង ។

## ការសន្និដ្ឋាន និងការវាយតំលៃរួម

និងសម្ព័ន្ធអង្គការសង្គមស៊ីវិល និងអង្គការសង្កេតការណ៍អន្តរជាតិភាគច្រើនបានវាយតំលៃលើ ដំណើរការបោះឆ្នោត ពិសេសនីតិវិធីថ្ងៃបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងស្ថានភាពក្រោយការបោះឆ្នោតដែលបានប្រព្រឹត្តក្រោម បរិយាកាសមានសន្តិសុខល្អ។ ប៉ុន្តែស្ថានភាពនយោបាយនៅតែមិនទាន់ឈានដល់កំរិតនៃការបោះឆ្នោត ដោយសេរី និងយុត្តិធម៌ពិតប្រាកដនៅឡើយ។ មានករណីនៃអំពើហិង្សាមួយចំនួនបានកើតឡើងផងដែរនៅមុនថ្ងៃ បោះឆ្នោត ពិសេស គឺ ការគំរាមកំហែង ការរារាំងដល់ការចូលរួមក្នុងសកម្មភាពនយោបាយ និងសេរីភាពខាងការបញ្ចេញមតិ។ អ្នកបោះឆ្នោត នៅតែត្រូវបានគាបសង្កត់ក្នុងការសំរេចចិត្តជ្រើសរើសគណបក្សនយោបាយតាមការពេញចិត្តរបស់ខ្លួន ហើយមិនបានទទួល ព័ត៌មានបានគ្រប់ជ្រុងជ្រោយ។ ប្រជាពលរដ្ឋ អ្នកបោះឆ្នោតនៅតែមានការភ័យខ្លាច អ្នកដឹកនាំដែលមានអំណាចអាច គំរាម កំហែងដល់អាយុជីវិតផ្ទាល់ខ្លួនព្រមទាំងក្រុមគ្រួសារ។




សន្និសីទសារព័ត៌មានរបស់សម្ព័ន្ធអង្គការសង្កេតការណ៍បោះឆ្នោត

ចំនួនករណីនៃអំពើឃាតកម្ម ការគំរាមកំហែង និងភាពមិនប្រក្រតីក្នុងដំណើរការបោះឆ្នោតមានការថយចុះ ជាងការបោះឆ្នោតលើកមុន ប៉ុន្តែនៅមិនទាន់មាន វិធានការផ្លូវច្បាប់ ការចោទប្រកាន់ការស៊ើបអង្កេតត្រឹមត្រូវតាមនីតិវិធី ដែលធ្វើឱ្យវប្បធម៌និទណ្ឌភាពនៅកើតមានជាបន្ត។

មានករណីឃាតកម្មការគំរាមកំហែងចំនួន៥៨ករណីទៅលើបេក្ខជន និងសកម្មជននយោបាយអ្នកសារព័ត៌មាន និងអ្នកបោះឆ្នោតបានកើតឡើងនៅស្ទើរតែគ្រប់ខេត្ត-ក្រុង។

តាមការវាយតំលៃជារួមរបស់ខុមហ្វ្រែល និងអង្គការសង្គមស៊ីវិល

ទៅលើដំណើការបោះឆ្នោតនោះគឺភាពមិន ប្រក្រតីនៅតែកើតមានឡើង ពិសេសនៅដំណាក់កាលមុនពេលបោះឆ្នោត។ មានអ្នកបោះឆ្នោតជាច្រើនបានទៅបោះឆ្នោត ហើយមិនបានបោះឆ្នោត ដោយសារជួបឧបសគ្គផ្សេងៗ។ តាមការវាយតំលៃអ្នកដែលមិនបានប្រើប្រាស់សិទ្ធិបោះឆ្នោត គឺមានកំរិតខ្ពស់ ដោយការគ្មានការទទួលខុសត្រូវរបស់មន្ត្រីរៀបចំការបោះឆ្នោត គ្រប់លំដាប់ថ្នាក់ និងអាជ្ញាធរដែនដី ក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះអ្នកបោះឆ្នោត ការសំអាតបញ្ជីឈ្មោះ អ្នកបោះឆ្នោត ការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត និងការចេញទំរង់១០១៨ ដែលបង្កឱ្យមានភាព មិនប្រក្រតី និងការចោទប្រកាន់មួយចំនួន។

ជាមួយនឹងភាពមិនប្រក្រតីនេះ លោក ប្រធានគណៈកម្មាធិការនាយក និងប្រធានសមាគម បានមានប្រសាសន៍ថាៈ បញ្ជីបោះឆ្នោតថ្មីមួយគួរតែត្រូវបានរៀបចំ ហើយបទបញ្ជា និងនីតិវិធីត្រូវធ្វើវិសោធនកម្ម ដើម្បីចេញប័ណ្ណបោះឆ្នោត ឬឯកសារសំរាប់បោះឆ្នោតជាអចិន្ត្រៃយ៍ ជាមួយនឹងព័ត៌មានច្បាស់លាស់ អំពីទីតាំងការិយាល័យ បោះឆ្នោត ដែលធ្វើឱ្យអ្នកបោះឆ្នោតមានភាពងាយស្រួលក្នុងការបោះឆ្នោត។

## TsSnvsysrabkare)aHeqatX-sgat2012 ngkare)aHeqat tNagra®s2013

ការបោះឆ្នោតជាតិឆ្នាំ២០០៨នេះបានបង្ហាញពីការធ្លាក់ចុះយ៉ាងខ្លាំងរបស់គណបក្ស និងការចុះខ្សោយរបស់គណបក្សប្រឆាំង ដែលជាគោលបំណងយ៉ាងជាក់ច្បាស់របស់អ្នកដឹកនាំគណបក្សប្រជាជនកម្ពុជា។ ជាការពិតណាស់ ដែលថាកម្ពុជាអាចនឹងវិលត្រឡប់ទៅកាន់ ឯកបក្សជាជាងប្រព័ន្ធប្រជាធិបតេយ្យដែលមានគណបក្សនយោបាយធំៗ ចំនួន ពីរនោះ។ ប្រព័ន្ធអភិបាលកិច្ច និងប្រជាធិបតេយ្យអាស្រ័យដោយដំណើរការរបស់ស្ថាប័នរដ្ឋ និងគោលការណ៍តុល្យភាពនៃ អំណាចរវាងអំណាចនីតិប្រតិបត្តិ និងគណបក្សប្រឆាំង។ ខាងក្រោមនេះជាលទ្ធភាពដែលអាចកើតមានឡើងនៅកម្ពុជា។

: ប្រសិនបើរូបមន្តនៃការតែងតាំងសមាជិក ដោយសមាមាត្រអាសនៈតំណាងរាស្ត្រ ក្នុងរដ្ឋសភា នៅដដែលនោះគណបក្សប្រជាជនកម្ពុជានឹងមានអត្ថិភាពរហូតដល់៧៥%ក្នុងគ្រប់គ្រងស្ថាប័ននេះ។ ខុមហ្វ្រែល នៅតែរក្សាជំហរទាមទារឱ្យចែងក្នុងច្បាប់បោះឆ្នោតដែលសមាជិ គជប ត្រូវតែអព្យាក្រឹត ហើយគ្មាននិន្នាការនយោបាយ។ ករណី ដែលសមាជិក ទាំងអស់មកពីគណបក្សប្រជាជនកម្ពុជា នោះស្ថាប័ននេះនឹងមិនឯករាជភាព អព្យាក្រឹតភាព។

: អង្គបោះឆ្នោតក្នុងការជ្រើសរើសសមាជិកព្រឹទ្ធសភាគឺមានតំណាងរាស្ត្រក្នុងតំណែងដែលមាន សមាជិក គណបក្សប្រជាជនកម្ពុជា៧៣% និងសមាជិក ក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលមានសមាជិកគណបក្សប្រជាជនកម្ពុជា ៧០% នោះលទ្ធផលនៃការបោះឆ្នោតនឹងត្រូវបានគេគណនាដឹងជាមុនយ៉ាងជាក់ច្បាស់។ ប្រសិនបើព្រឹទ្ធសភា បំរើការក្នុងគោលដៅ ដែលមានន័យនេះ សមាជិកព្រឹទ្ធសភាត្រូវតែលើកឡើងនូវមតិ យោបល់ពិភាក្សា និងធ្វើការកែសំរួលលើអត្ថបទច្បាប់ ផ្សេងៗ មិនមែនត្រឹមតែចាំប្រថាប់ត្រាលើសេចក្តីសំរេចដែលរដ្ឋសភាមកពីគណបក្សតែមួយ បានអនុម័តនោះទេ។

: ផ្នែកមួយនៃនយោបាយកំណែទំរង់វិមជ្ឈការនោះគឺត្រូវធ្វើនៅថ្នាក់ រាជធានី ខេត្ត ក្រុង ស្រុក និងខ័ណ្ឌ។ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក និងខ័ណ្ឌ បានកំណត់អង្គបោះឆ្នោតប្រហាក់ប្រហែលនឹងការបោះឆ្នោតព្រឹទ្ធសភាដែរ។ ក្រុមប្រឹក្សាឃុំ-សង្កាត់ជាអាជ្ញាធររដ្ឋបាល ដែលមានកំរិតទាបណាស់ក្នុងការគ្រប់គ្រង និងផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព ដូចជា ការអប់រំសុខភាព និងគមនាគមន៍ជាដើម។ ដូចនេះ សេវាសាធារណៈថ្នាក់មូលដ្ឋានសំខាន់ៗគឺត្រូវតែគ្រប់គ្រងដោយ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក និងខ័ណ្ឌដែលជាស្ថាប័នមិនមានលក្ខណៈប្រជាធិបតេយ្យពេញលេញនេះ។

ខុំហ្វ្រែលនឹងនៅតែបន្តធ្វើការតស៊ូមតិដើម្បីទាមទារឱ្យមានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌតាមរយៈការបោះឆ្នោតឯកត្តនាម។

**អនុសាសន៍**

សម្ព័ន្ធអង្គការសង្គមស៊ីវិល សូមផ្តល់ជូនអនុសាសន៍ ជាអាទិភាពមួយចំនួន សម្រាប់កំណែទម្រង់ការបោះឆ្នោតនៅពេលអនាគត ដូចខាងក្រោម :

- *ភាគីពាក់ព័ន្ធការបោះឆ្នោតទាំងអស់ ត្រូវពិភាក្សាគ្នា អំពីការធ្វើកំណែទម្រង់ការចុះឈ្មោះអ្នកបោះឆ្នោត និងបញ្ជីឈ្មោះអ្នកបោះឆ្នោត និងពិចារណាអំពីការលុបចោលក្នុងការចេញ និងការប្រើ ប្រាស់ទម្រង់ ១០១៨។*

- ធ្វើកំណែទម្រង់ គ.ជ.ប និងយន្តការដោះស្រាយទំនាស់ និងបណ្តឹងបោះឆ្នោត ឱ្យមានលក្ខណៈ អព្យាក្រឹត និងទទួលបាននូវទំនុកចិត្តឡើងវិញពីភាគីពាក់ព័ន្ធនឹងការបោះឆ្នោត និងអ្នកបោះឆ្នោត ។
- គួរមានច្បាប់ស្តីពីថវិការបស់គណបក្សនយោបាយ ដែលបញ្ជាក់ឱ្យច្បាស់ពីការផ្តល់និង/ឬការហាម ប្រើ ប្រាស់ថវិការបស់រដ្ឋ (ជាតិ) ក្នុងការផ្តល់ផលប្រយោជន៍ដល់គណបក្សនយោបាយ ដើម្បីបង្កើនតម្លាភាព នៃការប្រើប្រាស់ថវិកាក្នុងការឃោសនាបោះឆ្នោត ។
- ពង្រឹងការអនុវត្តច្បាប់ និងសហលក្ខន្តិកៈដើម្បីពង្រឹងអព្យាក្រឹតភាពរបស់ចៅក្រម អាជ្ញាធរ និងកងកម្លាំងប្រដាប់អាវុធ រួមទាំងនគរបាលដែលមិនត្រូវឱ្យចូលរួមសកម្មភាពគាំទ្រគណបក្សនយោបាយ និងការឃោសនាបោះឆ្នោត (ទោះបីក្នុងម៉ោង ឬក្រៅម៉ោងធ្វើការ) ឱ្យមានប្រសិទ្ធភាព ។
- ពង្រឹងក្របខ័ណ្ឌច្បាប់សម្រាប់ប្រព័ន្ធផ្សព្វផ្សាយដើម្បីធានាការគោរពតាមគោលការណ៍ស្មើភាព សមធម៌ និង តុល្យភាពព័ត៌មានដល់គណបក្សនយោបាយប្រកួតប្រជែងការបោះឆ្នោតទាំងអស់ ។
- ប្រព័ន្ធបោះឆ្នោត គួរតែមានការពិនិត្យមើលឡើងវិញ ដើម្បីធ្វើយ៉ាងណាជំរុញទឹកចិត្តឱ្យមានបេក្ខជន ឯករាជ្យ ។ ប្រព័ន្ធបោះឆ្នោតគួរតែអនុវត្តទៅតាមប្រព័ន្ធបោះឆ្នោតចំរុះ (ប្រព័ន្ធឯកត្តនាម និងប្រព័ន្ធសមាមាត្រ រួមបញ្ចូលគ្នា និងបេក្ខជនដែលមកពីខាងគណបក្សនយោបាយ និងមិនមកពីខាងគណបក្សនយោបាយគួរតែ អាចចូលប្រកួតប្រជែងគ្នាបានក្នុងការបោះឆ្នោតនៅគ្រប់មណ្ឌល ទាំងអស់) ។
- ដើម្បីជំរុញឱ្យមានការចូលរួមកាន់តែច្រើនពីសំណាក់ស្ត្រី កូតាអប្បបរមា ៣០% គប្បីត្រូវអនុម័តសំរាប់ស្ថាប័នសាធារណៈ និងដាក់បញ្ចូលនៅក្នុងបទបញ្ជាសមាជិកភាពនៃគ្រប់គណបក្សនយោបាយទាំងអស់ដែល ត្រូវសម្រេច ឱ្យបាននៅឆ្នាំខាងមុខ ។
- រចនាសម្ព័ន្ធថ្នាក់ដឹកនាំរដ្ឋសភា គួរតែបង្កើតឡើងដោយផ្អែកលើ តុល្យភាពអំណាច និងការត្រួតពិនិត្យ ដ៏ត្រឹមត្រូវ រវាងគណបក្សកាន់អំណាច និងគណបក្សជំទាស់ ។ ធ្វើដូច្នេះអ្នកតំណាងមកពីគណបក្សនយោបាយជាប់ឆ្នោត ទាំងអស់ក្នុងរដ្ឋសភា គួរតែត្រូវបានជ្រើសរើស ធ្វើជាប្រធាន និងសមាជិកគណៈកម្ម ការជំនាញនានារបស់រដ្ឋសភា ។
- ចំនួនអាសនៈរដ្ឋសភា គួរតែបង្កើនរហូតដល់ ១៣០ ។ យោងទៅតាមអត្រាកំណើតរបស់ប្រជាជន, ទីតាំងភូមិសាស្ត្រ, កត្តាសេដ្ឋកិច្ច និងសង្គមក្នុងមណ្ឌលបោះឆ្នោតមួយចំនួន អសនៈនៃរដ្ឋសភា គួរតែត្រូវបានបន្ថែមយ៉ាងហោចណាស់ចំនួន ៧ សំរាប់មណ្ឌលបោះឆ្នោតដូចជាៈ បាត់ដំបង កំពង់ស្ពឺ កោះកុង ឧត្តរមានជ័យ ព្រះវិហារ សៀមរាប និងក្រុងព្រះសីហនុ ។

**សេចក្តីកែតម្រូវ**

ព្រឹត្តិបត្រអ្នកឃ្លាំមើលលេខ៣៥ ឆ្នាំទី១០ ចេញផ្សាយថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ក្នុងអត្ថបទដែលមាន ចំណងជើងថា ការបោះឆ្នោតនៅប្រទេសនេ ប៉ាល់ឆ្នាំ២០០៨ ត្រង់ទំព័រ២២ :

- បន្ទាត់ទី១០ ដែលមានខ្លឹមសារថា "ច្បាប់បោះឆ្នោត នេប៉ាល់កំណត់យកប្រព័ន្ធបោះឆ្នោតចំរុះដែមានប្រព័ន្ធ សមាមាត្រផង និងឯកត្តនាមផង ។ អាសនៈចំនួន២៤០ ត្រូវបានបោះឆ្នោតជ្រើសតាំងតាមប្រព័ន្ធឯកត្តនាម ហើយ អាសនៈចំនួន៣៣៥ ត្រូវបោះឆ្នោតតាមប្រព័ន្ធឯកត្តនាម "ត្រូវបានកែតម្រូវដូចតទៅ "ច្បាប់បោះឆ្នោតនេប៉ាល់កំណត់ យកប្រព័ន្ធបោះឆ្នោតចំរុះដែលមានប្រព័ន្ធសមាមាត្រផង និងឯកត្តនាមផង ។ អាសនៈចំនួន២៤០ ត្រូវបានបោះឆ្នោត ជ្រើសតាំងតាមប្រព័ន្ធឯកត្តនាម ហើយអាសនៈចំនួន៣៣៥ ត្រូវបោះឆ្នោតតាមប្រព័ន្ធសមាមាត្រ"។
- បន្ទាត់ទី២៣ ដែលមានខ្លឹមសារថា "...ដោយសារតំណាងនៅថ្នាក់ស្រុក និងឃុំគឺមានសមាជិកសភាធម្មនុញ្ញ ដែលជាប់ឆ្នោតតាមប្រព័ន្ធ សមាមាត្រហើយ..." ត្រូវបានកែតម្រូវដូចតទៅ "...ដោយសារតំណាងនៅថ្នាក់ស្រុក និងឃុំ គឺមានសមាជិកសភាធម្មនុញ្ញដែលជាប់ឆ្នោត តាមប្រព័ន្ធឯកត្តនាមហើយ..."។

# ការបោះឆ្នោតនៅប្រទេសនេប៉ាល់ឆ្នាំ២០០៨ (តចប់ពីលេខមុន)

ប្រព័ន្ធបោះឆ្នោតដែលអនុវត្តនៅប្រទេសនេប៉ាល់នេះគឺជួយគណបក្សតូចៗ ដែលទទួលបានសម្លេងឆ្នោតតិច អាចទទួលបានអាសនៈក្នុងសភាធម្មនុញ្ញផងដែលមានចំនួនគណបក្សនយោបាយរហូតដល់២៥ និងមានបេក្ខជនឯករាជ្យ ចំនួន២រូបផងដែរ។

## គណៈកម្មការរៀបចំការបោះឆ្នោត

គណៈកម្មការរៀបចំការបោះឆ្នោតមានចំនួន ៥រូប ដែលដឹកនាំដោយប្រធានមួយរូប និងសមាជិក៤រូប។ ប្រធាន និងសមាជិកទាំងអស់ត្រូវមានអាយុយ៉ាងតិច៤៥ឆ្នាំ ហើយមានសញ្ញាប័ត្រចាប់ពីអនុបណ្ឌិត (Master Degree) ឡើងទៅ។ សមាជិកទាំងអស់មានអាណត្តិ៦ឆ្នាំ ហើយត្រូវតែចូលនិវត្តន៍នៅអាយុ៦៥ឆ្នាំ។ គណៈកម្មការរៀបចំការបោះឆ្នោតជាស្ថាប័នដែលមាន***ចែងក្នុងរដ្ឋធម្មនុញ្ញ ឯករាជ និងអព្យាក្រឹត***។ តាមការស្ទង់មតិពីប្រជាពលរដ្ឋ នៅទីប្រជុំជន និងតំបន់ជនបទគឺគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ទទួលការជឿទុកចិត្តពីប្រជាពលរដ្ឋភាគច្រើន ថាប្រកាន់ជំហរឯករាជ្យ និងអព្យាក្រឹតពិតប្រាកដ ជាក់ស្តែងក្នុងចំណោមប្រជាពលរដ្ឋចំនួន១០ដែលត្រូវបានសំភាសគឺ មាន៩នាក់ឆ្លើយថាពួកគេមានការជឿជាក់លើអព្យាក្រឹតភាពរបស់គណៈកម្មការបោះឆ្នោត ហើយ១នាក់ឆ្លើយថាមិនដឹង។

រចនាសម្ព័ន្ធគណៈកម្មការរៀបចំការបោះឆ្នោតគឺមានថ្នាក់ជាតិ ថ្នាក់ស្រុក ថ្នាក់មណ្ឌល និងថ្នាក់ការិយាល័យ។

## ការឃោសនាបោះឆ្នោត

ការឃោសនាបោះឆ្នោតមានរយៈពេល១ខែ ហើយទុករយៈពេល២ថ្ងៃមិនឱ្យមានសកម្មភាពឃោសនា មុនថ្ងៃ បោះឆ្នោត (ការឃោសនាចាប់ពីថ្ងៃទី០៧ ខែមីនា ដល់០៧ ខែមេសា ឆ្នាំ២០០៨ ថ្ងៃទី០៨-០៩ ជាថ្ងៃស ហើយថ្ងៃ១០ ខែមេសា ឆ្នាំ២០០៨ ជាថ្ងៃបោះឆ្នោត)។

ច្បាប់បោះឆ្នោតបានកំណត់សំភារៈឃោសនាសំរាប់គណបក្សនយោបាយទាំងបរិមាណ ទំហំ និងគុណភាពទៀតផង ដូចជាចំពោះបេក្ខជនឯកត្តនាម (ទាំងបេក្ខជនមកពីគណបក្ស និងបេក្ខជនឯករាជ្យ) អាចប្រើប្រាស់តែម៉ូតូ ឬឡានសំរាប់ឃោសនាបានតែ១គ្រឿងប៉ុណ្ណោះ។ ចំពោះឯកសារបោះពុម្ព ដូចជាផ្ទាំងរូបភាព កម្មវិធីនយោបាយ គឺ គ្រប់គណបក្សនយោបាយអាចបោះពុម្ពលើក្រដាសតែ១ពណ៌ ហើយគុណភាពដូចគ្នាទាំងអស់ និងមានទំហំមិនលើស ពី ទំហំដែលច្បាប់បានកំណត់ (ប្រហែលក្រដាស A4)។ ប៉ុន្តែ ក្នុងការអនុវត្តចំណុចនេះ ឃើញមានការរំលោភដោយ គណបក្សម៉ៅនិយមនៅទីក្រុងក៏ដូចជានៅតាមបណ្តាស្រុកមួយចំនួនផងដែរ ហើយក្រោយការប្តឹងតវ៉ា និងការដោះស្រាយ គឺគណៈកម្មការរៀបចំការបោះឆ្នោតបានឱ្យគណបក្សទំលាក់ ឬដកយកឯកសារទាំងនោះទៅទុកវិញ។ ចំពោះការប្រើប្រាស់ទីកន្លែងសាធារណៈវិញ គឺអាជ្ញាធររដ្ឋបាលថ្នាក់ឃុំជាអ្នកសំរបសំរួលពេលវេលា និងទីកន្លែង។ ជោគជ័យធំបំផុតរបស់អាជ្ញាធរមូលដ្ឋានដែលជាអ្នកសំរបសំរួលនេះ គឺនៅតំបន់ជនបទ មិនឃើញមានការជាន់គ្នាទាំងទីកន្លែង និងពេលវេលាសំរាប់ឃោសនារបស់គណបក្សនយោបាយពីរ ឬច្រើនទេ ហើយក៏មិនឃើញមានទំនាស់កើត ឡើងដោយការប្រើប្រាស់ទីកន្លែងសាធារណៈនេះឡើយ ម្យ៉ាងទៀត តាមស្ទង់មតិរបស់ប្រជាពលរដ្ឋ ពិសេសនៅតំបន់ជនបទគឺពួកគេមានការជឿជាក់ខ្ពស់ណាស់ទៅលើអព្យាក្រឹតភាពរបស់អាជ្ញាធរមូលដ្ឋាន កងនគរបាល ក៏ដូចជាមន្ត្រី រៀបចំការបោះឆ្នោតផងដែរ។

វិធីសាស្ត្រឃោសនាដែលត្រូវបានយកមកប្រើច្រើនជាងគេ គឺការជួបជុំជាមហាមិទ្ទិញ និងការដើរឃោសនាតាមផ្ទះ។ ចំណែកឯការដង្ហែក្បួន និងសកម្មភាពផ្សេងទៀតត្រូវបានយកមកប្រើដែរ តែមិនសូវខ្លាំងក្លាពេកទេ។ ក្នុងសកម្មភាពឃោសនានីមួយៗ សង្កេតឃើញសកម្មជនគណបក្សនយោបាយជាស្ត្រី ពិសេសយុវនារីរបស់គណបក្ស ម៉ៅនិយម ចូលរួមយ៉ាងសកម្មគួរឱ្យចាប់អារម្មណ៍។

## នីតិវិធីថ្ងៃបោះឆ្នោត

ការបោះឆ្នោតប្រព្រឹត្តទៅនៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៨ ដោយចាប់ផ្តើមពីម៉ោង៧.០០នាទីព្រឹកដល់ម៉ោង ១៦.០០នាទីរសៀល។ នៅមុនពេលបើកការបោះឆ្នោត មន្ត្រីបោះឆ្នោតបានធ្វើការរៀបចំ និងត្រួតពិនិត្យឯកសារ និងសំភារៈបោះឆ្នោតសំខាន់ៗ ដូចជាសន្លឹកឆ្នោត បញ្ជីបោះឆ្នោត ហិបឆ្នោត ទឹកខ្មៅ។ សំភារៈដែលសំខាន់មួយទៀតដែរ នោះគឺ ត្រាពិណខៀវ តូច សំរាប់អ្នកបោះ

ឆ្នោតបោះត្រាលើគណបក្សនយោបាយដែលខ្លួនពេញចិត្តនៅលើសន្លឹកឆ្នោត (ដែលនៅកម្ពុជាយើងប្រើប៊ិចសំរាប់គូស)។

ការិយាល័យបោះឆ្នោតភាគច្រើនមានទីតាំងនៅក្នុងសាលារៀនសាធារណៈ ប៉ុន្តែត្រូវបានរៀបចំនៅទីធ្លាខាងក្រៅមុខបន្ទប់រៀន ដោយប្រើខ្សែសំរាប់កំណត់ព្រំប្រទល់ការិយាល័យបោះឆ្នោត។ អ្នកបោះឆ្នោតត្រូវឈរតំរង់ជួរនៅ ខាងមុខច្រកចូល ដោយត្រូវឈរជាពីរជួរ ដែលមានបុរសមួយជួរ ស្រ្តីមួយជួរផ្សេងគ្នា ហើយអ្នកបោះឆ្នោតចូលក្នុងការិយាល័យបោះឆ្នោតឆ្លាស់គ្នាបុរស និងស្រ្តី ដែលធ្វើអោយចំនួនអ្នកដែលបានបោះឆ្នោតជាបុរស និងស្រ្តីមានចំនួនស្មើគ្នា។

ចំពោះមន្ត្រីបោះឆ្នោតគឺមានសមាសភាព និងចំនួនប្រហាក់ប្រហែលកម្ពុជាយើងដែរ គឺមានមន្ត្រីផ្ទៀងផ្ទាត់ឯកសារបញ្ជាក់អត្តសញ្ញាណជាមួយនឹងទិន្នន័យក្នុងបញ្ជីបោះឆ្នោត មន្ត្រីផ្តល់សន្លឹកឆ្នោត និងមន្ត្រីត្រួតពិនិត្យហិបឆ្នោត។ ក្នុងចំណោមមន្ត្រីបោះឆ្នោតយើងឃើញមានតុល្យភាពរវាងមន្ត្រីជាបុរស និងស្ត្រីផងដែរ ជាពិសេស ចំពោះមន្ត្រីជ្រលក់ ទឹកខ្មៅគឺត្រូវតែជាស្រ្តីដាច់ខាត។ មន្ត្រីបោះឆ្នោតមានការបើកទូលាយដល់តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ អន្តរជាតិក្នុងការចូលរួមសង្កេតការណ៍ក្នុងដំណើរការបោះឆ្នោតទាំងមូល។ ចំពោះអ្នកសង្កេតការណ៍អន្តរ ជាតិដែលមានពាក់ប័ណ្ណសំគាល់ដែលទទួលស្គាល់ដោយគណៈកម្មការរៀបចំការបោះឆ្នោតហើយនោះ គឺទទួលការបង្ក លក្ខណៈងាយស្រួលក្នុងការបំពេញការងារដោយសេរី។

នៅក្នុងដំណើរការបោះឆ្នោត ភ្នាក់ងារគណបក្សនយោបាយអាចជួយដល់អ្នកបោះឆ្នោតក្នុងការរកឈ្មោះ និងលេខរៀងក្នុងបញ្ជីបោះឆ្នោត និងពីទីតាំងការិយាល័យបាន។ ជាពិសេស គឺគណបក្សនយោបាយមានបញ្ជីបោះឆ្នោត សំរាប់ការិយាល័យដែលខ្លួនធ្វើការសង្កេតការណ៍នោះ ដើម្បីផ្ទៀងផ្ទាត់ជាមួយអ្នកដែលបានមកបោះឆ្នោតជាក់ស្តែង។ ភ្នាក់ងារគណបក្សនយោបាយមានតួនាទីសំខាន់ក្នុងការពិភាក្សាផ្តល់យោបល់ក្នុងករណីដែលទិន្នន័យក្នុងឯកសារបញ្ជាក់ អត្តសញ្ញាណ និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត។ មន្ត្រីការិយាល័យបោះឆ្នោតទទួលយក និងអនុវត្តតាមការផ្តល់មតិ យោបល់របស់ភ្នាក់ងារគណបក្សនយោបាយភាគច្រើនក្នុងការសំរេចថាត្រូវអនុញ្ញាតឱ្យអ្នកបោះឆ្នោតដែលមានការ សង្ស័យបានបោះឆ្នោតឬមិនបានបោះឆ្នោត។

## ការរាប់សន្លឹកឆ្នោត

ក្រោយពីបញ្ចប់ការបោះឆ្នោត មន្ត្រីការិយាល័យត្រូវបញ្ជូនហិបឆ្នោតទៅស្នាក់ការមណ្ឌលបោះឆ្នោត ហើយ ត្រូវដឹកជញ្ជូនមកស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ស្រុក។ ការរាប់សន្លឹកឆ្នោតគឺធ្វើនៅថ្នាក់ស្រុកនេះ។ ក្នុងការដឹកជញ្ជូននេះ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អាចចូលរួមតាមដាន សង្កេតការណ៍បាន។ ដោយកត្តាភូមិសាស្ត្រប្រទេសនេប៉ាល់ ការដឹកជញ្ជូនហិបឆ្នោតពីការិយាល័យមកមណ្ឌល និងមកស្រុកគឺជួបការលំបាក មួយចំនួននៅតាមតំបន់ព្រៃភ្នំ ដែលមានហិបឆ្នោតខ្លះត្រូវការពេល២ ឬ ៣ថ្ងៃដើម្បីដឹកជញ្ជូនមកថ្នាក់ស្រុក ដែលជា កន្លែងរាប់សន្លឹកឆ្នោត។

ក្នុងការរាប់សន្លឹកឆ្នោតគឺគេយកសន្លឹកឆ្នោតចំនួន២ ឬ៣ការិយាល័យចាក់បញ្ចូលគ្នា ទើបចាប់ផ្តើមធ្វើការរាប់ ។ ការរាប់សន្លឹកឆ្នោតគឺត្រូវធ្វើជាប់រហូតអស់រយៈពេល៣ ឬ៤ថ្ងៃទើបបញ្ចប់ការរាប់សន្លឹកឆ្នោតទាំងអស់ក្នុងទូទាំងស្រុក។ លទ្ធផលនៃការរាប់សន្លឹកឆ្នោតត្រូវបានប្រកាសភ្លាមនៅស្ថានីយ៍រាប់សន្លឹកឆ្នោតទោះបីជាយប់ក៏ដោយ។ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បានចូលរួមតាមដានការរាប់សន្លឹកឆ្នោតនេះ។ ជាក់ស្តែងឃើញមានបេក្ខជន ឈរឈ្មោះគឺបានចូលរួមតាមដានដោយផ្ទាល់ក្នុងដំណើរការរាប់សន្លឹកឆ្នោត បូកសរុបលទ្ធផល និងប្រកាសលទ្ធលនៅ ថ្នាក់ស្រុកនេះតែម្តង។

## លទ្ធផល

ជាលទ្ធផលគឺមានគណបក្សនយោបាយចំនួន ២៥ បានជាប់ឆ្នោតមានអាសនៈក្នុងសភាធម្មនុញ្ញ ប៉ុន្តែមាន គណបក្សតែ៤ ទេដែលទទួលបានអាសនៈលើសពី៣០។ គណបក្សឈ្នះឆ្នោតគឺគណបក្សកុំម្មុយនីសនេប៉ាល់មៅនិយម ទទួលបាន២២០អាសនៈ (១២០អាសនៈឯកត្តនាម និង១០០អាសនៈសមាមាត្រ) គណបក្សសភានេប៉ាល់ទទួលបាន ១១០អាសនៈ (៣៧អាសនៈឯកត្តនាម និង៧៣អាសនៈសមាមាត្រ) គណបក្សកុំម្មុយនីសនេប៉ាល់ម៉ាក្ស-លេនីននិយម ទទួលបាន១០៣អាសនៈ(៣៣អាសនៈឯកត្តនាម និង៧០អាសនៈសមាមាត្រ) និងគណបក្សវេទិកាសិទ្ធិប្រជាជន ទទួលបាន៥២ (៣០អាសនៈឯកត្តនាម និង២២អាសនៈសមាមាត្រ)។ ក្រៅពីនេះ មានគណបក្សនយោបាយចំនួន២១ ផ្សេងទៀតដែលទទួលបានអាសនៈពី១ទៅ៩អាសនៈក្នុងសភាធម្មនុញ្ញ។

គួរកត់សម្គាល់ថា មូលហេតុដែលមានគណបក្សច្រើនមានឱកាសជាប់ឆ្នោតក្នុងសភាធម្មនុញ្ញ គឺដោយសារប្រព័ន្ធបោះឆ្នោត និងរូបមន្តបែងចែកអាសនៈ ដែលនឹងសិក្សាលំអិតដោយឡែក។

# ការកត់សំគាល់នៅលើដំណើរការ របស់សភានៅដើមអាណត្តិទី៤

**ការបង្កើតរដ្ឋសភានីតិកាលទី៤ ធ្វើបានរលូន តែបន្សល់ទុកនូវភាពចម្រូងចម្រាស**

សម័យប្រជុំលើកទីមួយ នៃរដ្ឋសភានីតិកាលទី៤ ដើម្បីសម្រេចសុពលភាពអ្នកតំណាងរាស្ត្របានធ្វើឡើងដោយរលូន បើទោះបីជាមានការធ្វើពហិការពីសមាជិកសភា ៣រូប មកពីគណបក្សសិទ្ធិមនុស្ស និងភាពចម្រូងចម្រាស ផ្នែកច្បាប់ខ្លះក៏ដោយ ។ ចំនួនតំណាងរាស្ត្រដែលប្រកាសសុពលភាព និងបានស្បថចូលកាន់តំណែងតែ១១៩ នាក់ បានចោទជាសំនួរថា តើរដ្ឋសភានីតិកាលទី ៤ត្រូវបានបង្កើតហើយមែនឬ?ព្រោះថា តាមសេចក្តីសម្រេច របស់ក្រុមប្រឹក្សា ធម្មនុញ្ញ (សេចក្តីសម្រេចលេខ ០៩៤០០៥/ ២០០៣ កបថ.ច ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០០៨) បានបកស្រាយថា:

វាក្យខ័ណ្ឌទី ១នៃមាត្រា ៧៦នៃរដ្ឋធម្មនុញ្ញចែងថា រដ្ឋសភាមានសមាជិកយ៉ាងតិច១២០រូប ។ ត្រង់នេះមានន័យថា យ៉ាងតិចណាស់ត្រូវមានសមាជិកជាតំណាងរាស្ត្រចំនួន ១២០រូប ទើបអាចបង្កើតរដ្ឋសភាក្នុងនីតិកាលនីមួយៗបាន ទោះបីយ៉ាងណា នៅព្រឹកថ្ងៃទី២៥ ខែកញ្ញា រដ្ឋសភាក្រោមផ្លាកនីតិកាលទី ៤ បានបើកសម័យប្រជុំរបស់ខ្លួនដើម្បីអនុម័ត ការបោះឆ្នោតជាកញ្ចប់ជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងរាជរដ្ឋាភិបាល ។ ទោះបីជា សេចក្តីសម្រេច ដដែលរបស់ក្រុមប្រឹក្សាធម្មនុញ្ញចែងបន្តទៀត" វាក្យខ័ណ្ឌទី ១ (សមាជិក ១២០រូប)នេះ ជាល័ក្ខខ័ណ្ឌ ចាំបាច់សម្រាប់ការបង្កើត រដ្ឋសភាប៉ុន្តែ រដ្ឋសភានីតិកាលទី ៤ មិនទាន់នឹងបានបង្កើតផង តើអាចដំណើរការបានដោយរបៀបណា? ព្រោះថា តំណាងរាស្ត្រ ៤ រូប ផ្សេងទៀតសុទ្ធតែបានស្បថចូលកាន់តំណែងក្រោយថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨។ អ្នកតំណាង រាស្ត្រចំនួន ១១៩ រូបមកពី ៤ គណបក្ស បានចូលរួមសម័យប្រជុំសភាលើកទី ១ និងស្បថចូលកាន់តំណែងកាលពីថ្ងៃទី២៤ កញ្ញាក្នុងនោះមាន គណបក្សប្រជាជនកម្ពុជា ៩០រូប ហ៊្វុនស៊ិនប៉ិច ២រូប នរោត្តមរណឫទ្ធិ ២រូប និងសមរង្ស៊ី ២៥រូប (អវត្តមាន ១រូប) ដែលបានសម្រេចចិត្តចូលរួមប្រជុំភ្លាមៗមុនកិច្ចប្រជុំចាប់ផ្តើមបន្តិច ។ គួររំលឹកផងដែរថា គណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្ស បានរួមគ្នាជំទាស់នឹងលទ្ធផលបោះឆ្នោតតាំងតែពីក្រោយការប្រកាសលទ្ធផលបណ្តោះ អាសន្ននិងបានរួមគ្នាព្រមានថានឹងធ្វើពហិការសម័យប្រជុំសភា។ តែនៅនាទីចុងក្រោយព្រឹកថ្ងៃទី២៤ ខែកញ្ញា អ្នកតំណាងរាស្ត្រគណបក្ស សមរង្ស៊ី ចំនួន ២៥រូបបានចូលរួមសម័យប្រជុំនេះដែរ ដោយស្លៀកពាក់សំលៀកបំពាក់ធម្មតា ខណៈដែល អ្នកតំណាង រាស្ត្រ ៩៤ រូបផ្សេងទៀត ស្លៀកឯកសណ្ឋានតំណាងរាស្ត្រ ។អ្នកតំណាងរាស្ត្រគណបក្ស សមរង្ស៊ី បានការពារខ្លួនថាការចូល រួមប្រជុំនោះគឺដោយសារតែមានកិច្ចព្រមព្រៀងនយោបាយមួយចំនួន ដែលក្នុងនោះ គណបក្សប្រជាជនកម្ពុជាបានសន្យាថា នឹងធ្វើវិសោធនកម្មមាត្រាមួយចំនួននៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភាផងដែរដូច ជាការទទួល ស្គាល់តួនាទីរបស់គណបក្ស ប្រឆាំងនៅក្នុង រដ្ឋសភាជាដើម ។ ទោះបីជាមានការអះអាងបែបនេះក៏ដោយ រហូតមកដល់ពេលនេះបទបញ្ជាផ្ទៃក្នុង មិនទាន់ត្រូវបានធ្វើវិសោធនកម្មដើម្បីទទួលស្គាល់ និងផ្តល់អំណាចដល់គណបក្សប្រឆាំងក្នុងសភានៅឡើយទេ។ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាកាលពីថ្ងៃទី២៨ ខែតុលា ក៏បានបដិសេធសំណើធ្វើវិសោធនកម្មនេះពីតំណាងរាស្ត្រ គណបក្សជំទាស់សមរង្ស៊ីផងដែរ។ មន្ត្រីជាន់ខ្ពស់គណបក្ស ប្រជាជនកម្ពុជា និងជាសមាជិក គណៈកម្មាធិការអចិន្ត្រៃយ៍ រដ្ឋសភាអ្នកតំណាងរាស្ត្រ ត្រូវបានប្រព័ន្ធផ្សព្វផ្សាយ ស្រង់សម្តីថាការ ស្នើធ្វើ វិសោធនកម្ម បទបញ្ជាផ្ទៃក្នុងរដ្ឋសភាដោយគណបក្សជំទាស់មិនអាចទទួលយកបានឡើយ ព្រោះខុសនីតិវិធី ដោយ សារអ្នកតំណាងរាស្ត្រដែលស្នើធ្វើ វិសោធនកម្មមិនគ្រប់ចំនួន ៣១ រូប (១/៤ នៃចំនួនសមាជិកសភា សរុប)។ ដោយឡែក តំណាងរាស្ត្ររបស់គណបក្ស សិទ្ធិមនុស្ស ត្រូវបានប្រកាសសុពលភាព និងស្បថចូលកាន់តំណែងនៅថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០០៨ហើយអ្នកតំណាង រាស្ត្រជូឡុង សូមូរ៉ា មកពីគណបក្សសមរង្ស៊ីបានស្បថចូលកាន់តំណែងនៅថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០០៨។

**រដ្ឋសភាស្ថិតក្រោមការត្រួតត្រារបស់គណបក្សប្រជាជនកម្ពុជា**

សមាជិកសភាគណបក្សប្រជាជនកម្ពុជា បានកាន់កាប់តំណែងប្រធាន អនុប្រធានរដ្ឋសភា គណៈកម្មាធិការ អចិន្ត្រៃយ៍ និងគណៈកម្មការជំនាញទាំងអស់របស់រដ្ឋសភា ។ការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភាជាកញ្ចប់កាលពី ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ បានជ្រើសតាំងប្រធាន និងអនុប្រធាន រដ្ឋសភាទាំងពីរមកពីគណបក្សប្រជាជនកម្ពុជា និងប្រធាន និងអនុប្រធានគណៈកម្មការជំនាញនីមួយៗរបស់រដ្ឋសភា ក៏មកពីគណបក្ស ប្រជាជនកម្ពុជាផងដែរដែលខុស ពីនីតិកាលទី ១, ២ និង ៣ ដែលតំណែងទាំងនេះមានការ

បែងចែករវាងគណបក្សទាំងអស់ ដែលជាប់ឆ្នោត។ ការត្រួតពិនិត្យ និងតុល្យភាពអំណាចរវាងស្ថាប័ននីតិបញ្ញត្តិ និងនីតិប្រតិបត្តិបានក្លាយជាកង្វល់ដ៏ចម្បងមួយ។ ជាមួយគ្នានេះ សមាជិកគណៈកម្មការនីមួយៗ គឺសុទ្ធតែមកពីគណបក្សកាន់អំណាចប្រជាជនកម្ពុជាលើកលែងតែ គណៈកម្មការ ទី៤ ដែលមានសមាជិកមួយរូបមកពីគណបក្ស នរោត្តមរណឫទ្ធិនិង គណៈកម្មការទី ៩ដែលសមាជិកមួយរូបមកពីគណបក្ស ហ៊្វុនស៊ិនប៉ិច។ ការអង្កេត ទៅលើសកម្មភាពសមាជិកសភាក្នុងនីតិកាលទី ៣ កន្លងមកបានបង្ហាញថា សមាជិកសភាមកពីគណបក្ស ប្រជាជនកម្ពុជា រួមទាំងប្រធាន និងអនុប្រធានគណៈកម្មការជំនាញផងដែរ មិនដែលបានធ្វើការសួរដេញ ដោលទៅលើការងាររបស់រាជរដ្ឋាភិបាលនោះទេ ខណៈដែលតំណាងរាស្ត្រគណបក្សជំទាស់ ជារឿយៗបានអញ្ជើញ និងកោះហៅសមាជិករាជរដ្ឋាភិបាលមកបំភ្លឺជុំវិញការងារ និងភាពមិនប្រក្រតីនានារបស់រាជរដ្ឋាភិបាល។

**តំណាងរាស្ត្រជំទាស់មិនមានវត្តមានក្នុងសិក្ខាសាលាស្តីពីការស្វាគមន៍ និងតួនាទីតំណាងរាស្ត្រ**



សមាជិកសភាគណបក្សសមរង្ស៊ីបានធ្វើពហិការចូលរួមសិក្ខាសាលាណែនាំ និងតួនាទីរបស់តំណាងរាស្ត្រនីតិកាលទី៤ បើទោះ ជាតំណាងរាស្ត្រចំនួន២រូប ត្រូវបានផ្តល់ឱកាសឱ្យធ្វើជាវាគ្មិនក៏ដោយ។ អ្នកតំណាងរាស្ត្រ ដែល ត្រូវបានអញ្ជើញជាវាគ្មិនលើប្រធានបទការត្រួតពិនិត្យរបស់រដ្ឋសភា នៅក្នុងគណៈកម្មការជំនាញ និងការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្របាន ឱ្យដឹងពីការធ្វើ ពហិការនេះថា ព្រោះគណបក្សសមរង្ស៊ី ចង់ឱ្យមានការរៀបចំ បទបញ្ជាផ្ទៃ ក្នុងរដ្ឋសភា ដោយធ្វើវិសោធនកម្មធានាឱ្យមានតួនាទីរបស់គណបក្សប្រឆាំងនៅក្នុងរដ្ឋសភាសិន ព្រោះថា សិក្ខាសាលា បែបនេះមាន ច្រើនដងមកហើយ តែមិនមានប្រសិទ្ធភាពទេ។ ចំណែក តំណាងរាស្ត្រ **សុន ឆ័យ** ក៏ត្រូវបានអញ្ជើញជាវាគ្មិន នៅក្នុងប្រធានបទស្តីពីតួនាទីរបស់គណបក្សប្រឆាំងនៅក្នុងសភាប្រជាធិតេយ្យផងដែរ។ សិក្ខាសាលា ស្វាគមន៍ និងតួនាទីរបស់សមាជិករដ្ឋសភានីតិកាលទី៤នេះដែលរៀបចំឡើងដោយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ជួយផ្តល់ព័ត៌មាន ចំណេះដឹងថ្មីៗ ក៏ដូចជាបទពិសោធន៍ដំណើរការសភារបស់ប្រទេសផ្សេងៗសម្រាប់អ្នកតំណាងរាស្ត្រកម្ពុជា។

**អ្នកជំនាញការសភាអីរ៉ុបៈ តំណាងរាស្ត្រគណបក្សមិនបំពេញតួនាទីឱ្យបានល្អ**

អតីតអ្នកតំណាងរាស្ត្រប្រទេសអៀរឡង់ និងជាអ្នកជំនាញការរបស់ក្រុមសភាជាតិកម្ពុជានៃ សហភាពអន្តរ សភា (IPU) លោក ប៉ូលម៉ាក់ក្រាន(Paul McGranth) បានឱ្យដឹងថាសមាជិកសភាកម្ពុជាមិនបាន បំពេញតួនាទី ឱ្យ បានល្អក្នុងការអនុម័តច្បាប់ទេ។ "ច្បាប់ដែល រដ្ឋាភិបាលដាក់មកសភាអនុម័តគឺមិនត្រូវបានយកមកកែ ឬពិភាក្សា ហើយសិក្សាឱ្យបានស៊ីជម្រៅពីផលប៉ះពាល់នៅថ្ងៃមុខ គឺអនុម័តយកតែម្តង"។ លោក **ប៉ូល** បានថ្លែងបែបនេះនៅពេលដែលលោកត្រូវបាន អញ្ជើញធ្វើជាវាគ្មិននៅក្នុងសិក្ខាសាលាស្វាគមន៍ និងតួនាទីរបស់សមាជិករដ្ឋសភានីតិកាលទី៤ ដោយ ឱ្យរូបលោកចែករំលែកបទពិសោធន៍ពីក្រៅប្រទេស។ លោកក៏បានរិះគន់សមាជិកសភាមកពីគណបក្សកាន់អំណាចដែរថា មិនដែលហៅរដ្ឋាភិបាលមកសួរពីបញ្ហា ផ្សេងៗដែលកើតមានទេ។ លោក **ប៉ូល** បានឱ្យដឹងទៀតថា សមាជិកសភា មិនថា មកពីគណបក្សជំទាស់ ឬកាន់អំណាចទេត្រូវនៅឯករាជពីរាជរដ្ឋាភិបាល លោកបានលើកឡើងពីបទពិសោធន៍ពេលលោក នៅជាតំណាងរាស្ត្រថា "ខ្ញុំមកពី គណបក្សកាន់អំណាច តែខ្ញុំតែងហៅរដ្ឋាភិបាលមកសួរជាច្រើនសំនួរប្រសិនបើរដ្ឋាភិបាល ធ្វើអ្វីប៉ះពាល់ប្រជាជន ឬចង់ដឹងពីការងាររដ្ឋាភិបាល"។

**ការអនុម័តនានាដោយរដ្ឋសភា**



*ការបោះឆ្នោតជាកញ្ចប់កន្លងមក*

រដ្ឋសភាបានបើកសម័យប្រជុំចំនួន ៥ ព្រឹក ដោយបានអនុម័តទៅលើរបៀបវារៈសរុបចំនួន ៩ ដែលក្នុងនោះ របៀបវារៈ សំខាន់ៗ រួមមានៈ

- សម្រេចសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ ។
- ការអនុម័តបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ។
- ការបោះឆ្នោតជាកញ្ចប់ដើម្បីជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភាប្រធាន អនុប្រធានគណៈកម្មការជំនាញ នៃរដ្ឋសភានិង ផ្តល់សេចក្តីទុកចិត្តដល់រាជរដ្ឋាភិបាល ។
- ការទទួលស្គាល់តំណាងរាស្ត្រថ្មីគណបក្សប្រជាជនកម្ពុជា ជំនួសអ្នកតំណាងរាស្ត្រដែលបានសុំលាលែង ។

- ការបោះឆ្នោតជ្រើសតាំងលេខាធិការ និងសមាជិកគណៈកម្មការជំនាញនៃរដ្ឋសភា។

## អ្នកតំណាងរាស្ត្រស្ត្រីកើនឡើងដល់ ២២%



ការដោះដូរតំណាងរាស្ត្រក្នុងគណបក្សបានធ្វើឱ្យចំនួនតំណាងរាស្ត្រស្ត្រីមានការកើនឡើងគួឱ្យកត់សម្គាល់។ នៅថ្ងៃប្រកាស សុពលភាព និងស្បថចូលកាន់តំណែងតំណាងរាស្ត្រជាស្ត្រីសរុបមានចំនួនតែ ២០ រូបប៉ុណ្ណោះ។ ចំនួន តំណាងរាស្ត្រស្ត្រីបាន កើនឡើងដល់ ២៧ រូប( ស្មើនឹង ២២%នៃចំនួនតំណាងរាស្ត្រសរុប) ក្រោយពីគណបក្សប្រជាជនកម្ពុជា បានធ្វើការផ្លាស់ប្តូរអ្នកតំណាងរាស្ត្រចំនួន ២៦ រូបហើយ ជំនួសវិញនូវអ្នកតំណាងរាស្ត្រថ្មី ដែលមានស្ត្រីចំនួន ៧រូប។ រហូតមកដល់ពេលនេះតំណាងរាស្ត្រីមកពីគណបក្សប្រជាជនកម្ពុជាមានចំនួន ២១រូប ( ស្មើនឹង២៣% នៃ តំណាង រាស្ត្រគណបក្សនេះសរុប ៩០រូប)គណបក្ស សមរង្ស៊ី មាន៦រូប ( ស្មើនឹង ២៣%នៃតំណាងរាស្ត្រ គណបក្សនេះសរុបដែរ) ។ ចំណែកគណបក្ស ៣ផ្សេងទៀតមិនមានតំណាងរាស្ត្រស្ត្រីទេ។ ចំនួនតំណារាស្ត្រស្ត្រីមានការកើនឡើងជា លំដាប់ពី១អាណត្តិ ទៅមួយអាណត្តិពី ៦% ក្នុងអាណត្តិទី១ ទៅ១១% ក្នុងអាណត្តិទី ២ និងទៅ ២០% នៅអាណត្តិ ទី៣ ហើយអាណត្តិទី ៤ នេះមាន ២២%។ ដោយឡែកក្នុងនីតិកាលទី៤នេះមានអ្នកតំណាងរាស្ត្រយ៉ាងតិច ១២រូបដែលមាន តួនាទីក្នុង រាជរដ្ឋាភិបាល ក្នុងនោះមាន ២រូបជាស្ត្រីគឺ អ្នកតំណាងរាស្ត្រមណ្ឌលស្វាយរៀង ជាឧបនាយករដ្ឋមន្ត្រី និងអ្នកតំណាង រាស្ត្រមណ្ឌលកំពត ជារដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច។

## គណបក្សជាប់ឆ្នោតកើនឡើងជិតទ្វេដង

នីតិកាលទី ៤នេះគណបក្សក្នុងរដ្ឋសភាមានការកើន ឡើងរហូតដល់ ៥ គណបក្ស កើនលើសនីតិកាលទី៣ មាន តែ ៣ គណបក្សប៉ុណ្ណោះ។ ការកើនឡើងនៃចំនួនគណបក្សនេះត្រូវបានគេយល់ថា ប្រជាពលរដ្ឋមានជម្រើស និងចេះដឹង ចេះជ្រើសរើសគណបក្សដែលខ្លួនស្រឡាញ់។ទោះបីយ៉ាងណាក៏វាជាការបង្ហាញនូវក្តី បារម្ភថាការកើនឡើងនូវចំនួន គណបក្ស នេះនឹងអាចធ្វើឱ្យគណបក្សប្រឆាំងមានការចុះខ្សោយប្រសិនបើមិនបានរួបរួមគ្នាឱ្យល្អទេនោះ ខណៈដែល គណបក្ស កាន់អំណាចបានទទួលជ័យជំនះយ៉ាងច្រើនសន្ធឹកសន្ធាប់។ គណបក្សកាន់អំណាចប្រជាជនកម្ពុជាបាន ទទួល ជោគជ័យដោយមានសមាជិកសភាកើនពី ៧៣ រូបក្នុងនិតិកាលទី៣ ទៅ៩០រូប ក្នុងនីតិកាលទី៤នេះ ហើយគណបក្ស ជំទាស់ សម រង្ស៊ី បានកើតពីចំនួន២៤រូប ទៅ ២៦ រូបខណៈដែលគណបក្សហ៊្វុនស៊ិនប៉ិច បានធ្លាក់ចុះយ៉ាងខ្លាំងពី ២៦ រូប មកត្រឹមតែ២រូបប៉ុណ្ណោះ។ គណបក្សថ្មី ពីរទៀតដែលបានជាប់ឆ្នោត មានគណបក្សសិទ្ធិមនុស្ស ចំនួន ៣រូប និង គណបក្ស នរោត្តម រណឫទ្ធិចំនួន ២រូប។

**គណៈកម្មការព្រឹត្តិបត្រ**

គល់ បញ្ញា
ច័ន្ទ ដារិទ្ធ

ស្រី សុភ័ក្រ្ត

រស់ ស៊ីណាក់

comfrel@online.com.kh

www.comfrel.org

បើលោក អ្នកនាងកញ្ញាមានសំណូមពរ ចម្ងល់ ឬមានបំណងចូលរួមយោបល់ ឬស្នើសុំព្រឹត្តិបត្រសម្រាប់ស្ថាប័ន សូមទាក់ទងមកកាន់យើងខ្ញុំតាមរយៈអាសយដ្ឋានខាងលើនេះ។

ព្រឹត្តិបត្រ "អ្នកឃ្លាំមើល" ពីអង្គការសមាគម-មិនមែនរដ្ឋាភិបាល ទៅដល់ដៃប្រជាពលរដ្ឋនៅទូទាំងប្រទេស ដើម្បីភ្ជាប់ចន្លោះព័ត៌មានរវាងប្រជាពលរដ្ឋ និងអ្នកតំណាង និងអ្នកដឹកនាំពាក់ព័ន្ធក្នុងការចូលរួមស្ថាបនាសង្គមប្រជាធិបតេយ្យ ។

# សកម្មភាពការងាររបស់គណៈកម្មាធិការឃុំមប្រែប្រួល

VOC